**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economique

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ក្នុងក្របខណ្ឌច្បាប់កូវីដ-១៩

ស្រាវជ្រាវ ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ព្រំ គិតម៉ាន់**

សាស្រ្តាចារ្យណែនាំ

លោកស្រី **ជា សៀវម៉ី**


ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ


ខ្ញុំបាទឈ្មោះ ព្រំ គិតម៉ាន់ ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី ១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់:

- លោកឪពុក **ព្រំ ជា** និងអ្នកម្តាយ **ចិន ចន្ធួន** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ក៏ដូចជាលើកទឹកចិត្ត អប់រំទូន្មាន ប្រៀនប្រដៅ ផ្តល់នូវការស្រឡាញ់ ការយកចិត្តទុកដាក់ និងការផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាង ទាំងផ្នែកសំភារៈ និងស្មារតីអស់ពីកម្លាំងកាយចិត្តតាំងពីថ្ងៃចាប់កំណើតរហូតមកដល់ពេលបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឲ្យខ្ញុំបាទទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោក លោកស្រីដែលជាសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំ និងផ្តល់នូវចំណេះដឹងដល់ខ្ញុំបាទអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងផ្តល់នូវដំបូន្មាន ពាក្យអប់រំប្រដៅ និងទស្សនៈទានល្អៗជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍន៍ខ្លួនក្លាយទៅជាបុគ្គលដែលមានសមត្ថភាពមួយរូបក្នុងសង្គម។ អ្នកគ្រូសាស្ត្រាចារ្យ **ជា សៀវម៉ី** ដែលបានដឹកនាំ ចង្អុលបង្ហាញ ផ្តល់គំនិតយោបល់អំពីវិធីសាស្ត្រ និងកែសម្រួល រៀបចំនូវសារណាបញ្ចប់ការសិក្សាមួយនេះឲ្យបានជោគជ័យយ៉ាងប្រសើរ។
- រៀមច្បងជំនាន់មុនដែលបានបន្សល់ទុកនូវស្នាដៃល្អៗ ដែលជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយយកមកធ្វើជាគំរូ និងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។
- ព្រមទាំងមិត្តភក្តិជាច្រើនទៀតដែលបានឆ្លៀតពេលវេលាដ៏មមាញឹក ជួយពិនិត្យ ផ្តល់យោបល់ និងកែសម្រួលអត្ថន័យ និងខ្លឹមសារនិក្ខេបបទបញ្ចប់ការសិក្សានេះឲ្យទទួលបាននូវសង្គតភាព សាមញ្ញ ដើម្បីផ្តល់ភាពងាយស្រួលដល់មិត្តអ្នកអាន។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យសិរីមង្គល វិបុលសុខជូនចំពោះអ្នកមានគុណទាំងអស់ឲ្យជួបប្រទះនឹងពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជំងឺកូវីដ-១៩ ត្រូវបានពិភពលោកទាំងមូលចាត់ទុកថាជាវិបត្តិសកល។ ពីព្រោះជំងឺនេះបានសម្លាប់ផ្ដាច់យកនូវអាយុជីវិតរបស់ប្រជាពលរដ្ឋតាមបណ្ដាប្រទេសទូទៅក្នុងពិភពលោកយើងនេះ។ មិនតែប៉ុណ្ណោះ តាមរយៈនៃការរាតត្បាតនៃជំងឺកូវីដ-១៩នេះ បានបង្កឱ្យមាននូវផលប៉ះពាល់យ៉ាងខ្លាំងទៅលើវិស័យសង្គមនិងសេដ្ឋកិច្ច ហើយសុខភាពសាធារណៈក៏ត្រូវបានបំផ្លាញយ៉ាងធ្ងន់ធ្ងរផងដែរ។

បន្ថែមពីនេះជំងឺកូវីដ-១៩ ក៏បានធ្វើឱ្យពិភពលោកទាំងមូលមានការប្រែប្រួល ជាពិសេសគឺការរស់នៅតាមគន្លងថ្មី។ ដោយសារតែជាបរិបទថ្មីមួយទៀតបានកើតឡើងក្នុងប្រវត្តិសាស្ត្រមនុស្សជាតិយើងនេះហើយ ទើបបណ្ដាប្រទេសនីមួយៗបានចាប់ផ្ដើមដាក់ចេញនូវវិធានការផ្សេងៗ និងរៀងៗខ្លួនដើម្បីប្រយុទ្ធប្រឆាំងទៅនឹងជំងឺនេះ។ វិធានការនេះសោត មានលក្ខណៈខុសៗគ្នាដែលប្រទេសខ្លះប្រើប្រាស់ច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន វិធានការបិទខ្ទប់ និងវិធានការផ្សេងៗទៀតសំដៅដល់ការប្រយុទ្ធប្រឆាំងទៅនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។ តាមរយៈនៃការប្រើប្រាស់ច្បាប់ និងវិធានការទាំងនេះបានធ្វើឱ្យមាននូវផលប៉ះពាល់មួយចំនួនទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជាពិសេសក្នុងកំឡុងពេលអនុវត្ត។

ប្រទេសកម្ពុជាបច្ចុប្បន្ន នៅពេលដែលជំងឺនេះឆ្លងមកដល់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការផ្សេងៗសម្រាប់ការទប់ស្កាត់នៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ មកក្នុងសហគមន៍។ ប៉ុន្តែដោយសារតែមាននូវការលេចឡើងនូវការឆ្លងសហគមន៍ នឹងដែលត្រូវបានរាជរដ្ឋាភិបាលប្រសិទ្ធិនាមថាព្រឹត្តិការណ៍ឆ្លងសហគមន៍២០កុម្ភៈ ទើបប្រទេសកម្ពុជាបានបង្កើតនូវច្បាប់ពិសេសដាច់ដោយឡែកមួយគឺច្បាប់ប្រឆាំងកូវីដ-១៩។ ច្បាប់នេះមានចែងអំពីវិធានការសុខាភិបាល និងវិធានការរដ្ឋបាលដែលមានដូចជា ការរឹតត្បិត ឬហាមឃាត់ការដំណើរ ការជួបជុំ ការបិទខ្ទប់ និងបម្រាមគោចរ។ល។ ព្រមទាំងបទបញ្ញត្តិ និងទោសទណ្ឌមួយចំនួនទៀតចំពោះបុគ្គលណាដែលមិនគោរព និងអនុវត្ត។ ការណ៍នេះហើយត្រូវបានមជ្ឈដ្ឋានអន្តរជាតិ និងសង្គមស៊ីវិលចាត់ទុកថាការបង្កើត និងអនុម័តឱ្យប្រើប្រាស់ច្បាប់នេះហាក់មានការរំលោភបំពានទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ដោយស្ថិតក្នុងបរិបទនៃជំងឺកូវីដ-១៩ និងដែលជាប្រធានបទថ្មីបានកើតឡើងក្នុងស្ថានភាពបច្ចុប្បន្ននេះផ្ទាល់ ដូច្នេះហើយទើបខ្ញុំបាទសម្រេចចិត្តធ្វើកិច្ចការស្រាវជ្រាវ ឬសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ " សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌច្បាប់កូវីដ-១៩ " ដើម្បីបញ្ចប់ឆ្នាំសិក្សានារយៈកាលបួនឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ម៉្យាងវិញទៀតក្នុងការសរសេរអាចមានការប្រើពាក្យពុំចំដោយអចេតនា ហើយការខុសឆ្គងគឺជាប្រការដែលជៀសមិនផុត។

អាស្រ័យហេតុនេះខ្ញុំបាទសុំខន្តីអភ័យទោស និងសូមអធ្យាស្រ័យទុកជាមុននូវរាល់កំហុសឆ្គងនានាដែលនឹងអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ រួមមានការរៀបរៀង អត្ថន័យ និងជាពិសេសអក្ខរាវិរុទ្ធ។ ក្នុងន័យនេះដែរខ្ញុំបាទសូមស្វាគមន៍នូវរាល់ការរិះគន់ និងផ្តល់យោបលស្ថាបនាពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់ផងដែរ ដើម្បីធ្វើឱ្យកិច្ចការស្រាវជ្រាវនេះមានលក្ខណៈល្អប្រសើរ។ សូមមេត្តាអធ្យាស្រ័យដោយក្តីអនុគ្រោះអំពីខ្ញុំបាទផង។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ..........០១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ..........០២
៣. គោលបំណងនៃការស្រាវជ្រាវ..........០២
៤. ទំហំ និងព្រំដែនកំណត់នៃការស្រាវជ្រាវ..........០២
៥. វិធីសាស្រ្តក្នុងការស្រាវជ្រាវ..........០៣
៦. អត្ថប្រយោជន៍នៃការស្រាវជ្រាវ..........០៣
៧. រចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវ..........០៤

## ជំពូកទី ១

## ការសិក្សាអំពីទ្រឹស្តី

១.១. សេចក្តីផ្តើម..........០៦
១.២. និយមន័យសិទ្ធិ..........០៦
១.៣. សារៈសំខាន់..........០៧
១.៤. សិទ្ធិជាមូលដ្ឋាន..........០៨
១.៤.១. សិទ្ធិពលរដ្ឋ..........០៩
១.៤.២. សិទ្ធិនយោបាយ..........១០
១.៤.៣. សិទ្ធិសេដ្ឋកិច្ច..........១៣
១.៤.៤. សិទ្ធិសង្គម..........១៣
១.៤.៥. សិទ្ធិវប្បធម៌..........១៣
១.៥. ច្បាប់ សិទ្ធិ សេរីភាព និងករណីកិច្ច..........១៥

## ជំពូកទី ២

## ច្បាប់បទដ្ឋានផ្សេងៗដែលពាក់ព័ន្ធក្នុងបរិបទកូវីដ-១៩

២.១. រំលឹកអំពីសារតានៃជំងឺកូវីដ-១៩..........១៨
២.២. ការឆ្លងចូលនៃជំងឺកូវីដ-១៩មកក្នុងព្រះរាជាណាចក្រកម្ពុជា..........១៩

២.៣. ច្បាប់ប្រឆាំងកូវីដ-១៩ ........................................ ២១
២.៣.១. វិធានការសុខាភិបាល ........................................ ២៣
២.៣.២. វិធានការរដ្ឋបាល ........................................ ៣២

## ជំពូកទី ៣
## ផលប៉ះពាល់ទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋនៃច្បាប់ប្រឆាំងកូវីដ-១៩

៣.១. ទស្សនៈក្រុមអ្នកជំនាញសិទ្ធមនុស្ស អ.ស.ប ........................................ ៤០
៣.២. ទស្សនៈរបស់មន្ត្រីរាជរដ្ឋាភិបាល ........................................ ៤១
៣.៣. ទស្សនៈចម្រុះ ........................................ ៤៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ........................................ ៤៨
២. ការផ្តល់អនុសាសន៍ ........................................ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជំងឺកូវីដ-១៩ បាននឹងកំពុងបន្តរាតត្បាតពាសពេញពិភពលោក មិនថាតែប្រទេសអ្នកមាន និងប្រទេសអ្នកក្រ ឬ ប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍឡើយ។ ជំងឺកូវីដ-១៩ ដែលបានកើតឡើងតាំងពីចុងខែធ្នូ ឆ្នាំ២០១៩ មកទល់ពេលនេះមានអ្នកឆ្លងដោយសារជំងឺនេះប្រមាណរាប់សិបលាននាក់លើពិភពលោក និងដែលអាចចាត់ទុកបានថាជាជំងឺឆ្លងដ៏កាចសាហាវមួយដែលបានផ្តាច់ជីវិតមនុស្សច្រើនជាងគេក្នុងសតវត្សចុងក្រោយនេះ។ មិនតែប៉ុណ្ណោះកូវីដ១៩ បានដាក់ពិភពលោកទាំងមូលទៅក្នុងបរិបទថ្មីមួយឲ្យរស់នៅតាមបែបគន្លងថ្មី មិនថាតែការបំពេញការងារ ការសិក្សារៀនសូត្រ និងអ្វីៗផ្សេងទៀតត្រូវរក្សាគម្លាត ដោយអនុលោមតាមការណែនាំរបស់អង្គការសុខភាពពិភពលោក WHO។ លើសពីនេះទៅទៀតសេដ្ឋកិច្ច នយោបាយ និងសង្គម ក៏មានការប្រែប្រួលជាច្រើនផងដែរ។ ដោយឡែកបើយើងក្រឡេកមកមើលប្រទេសកម្ពុជារបស់យើងវិញឃើញថា មានអ្នកឆ្លងបន្តិចបន្តួចបើធៀបទៅនឹងបណ្តាប្រទេសដទៃទៀតទាំងនៅក្នុងតំបន់ ឬក្រៅតំបន់។

ទន្ទឹមនឹងនេះការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ១៩ របស់ប្រទេសកម្ពុជាគឺមានភាពល្អប្រសើរជាច្រើនដោយមានការចូលរួមពីសំណាក់ប្រជាជនកម្ពុជាទាំងមូលនិងដោយមានការចូលរួមពីសំណាក់ស្ថាប័នគ្រប់ជាន់ថ្នាក់ជាពិសេសគឺការណែនាំរបស់ក្រសួងសុខាភិបាល។ ក៏ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍២០ កុម្ភៈ រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានជួបនូវបញ្ហាដ៏ធំនោះ គឺការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ចូលមកក្នុងសហគមន៍ ដែលបង្កឲ្យជាតិរងនូវផលប៉ះពាល់យ៉ាងខ្លាំងទៅលើបញ្ហាសង្គម ក៏ដូចជាសុខភាពសាធារណៈ។ ចំពោះបញ្ហាសេដ្ឋកិច្ច និង ទេសចរណ៍របស់ប្រទេសកម្ពុជាក៏មានការរងផលប៉ះពាល់ផងដែរ។ តាមរយៈនេះដែរ ដោយសារតែមាននូវការឆ្លងរីករាលដាលយ៉ាងខ្លាំងនៅក្នុងសហគមន៍ ទើបរាជរដ្ឋាភិបាល បានធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអសន្ន សម្រាប់ប្រយុទ្ធប្រឆាំងទៅនឹងជំងឺឆ្លងដ៏កាចសាហាវកូវីដ-១៩។ យ៉ាងណាក៏ដោយ បន្ទាប់ពីបានឆ្លងកាត់ការនូវបទពិសោធន៍ ឬ កិច្ចពិភាក្សារួចមក ទើបរាជរដ្ឋាភិបាលកម្ពុជា សម្រេចចេញបាននូវច្បាប់បទដ្ឋានថ្មីមួយទៀតគឺ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ដើម្បីគ្រប់គ្រង ក៏ដូចជាឆ្លើយតបទៅនឹងសភាពការណ៍។ នៅក្នុងច្បាប់នេះទៀតសោត បានកំណត់អំពីវិធានការសុខាភិបាល និងវិធានការរដ្ឋបាល ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ប្រទេសមួយកាលណាបើគ្មានច្បាប់បទដ្ឋានអ្វីទាល់តែសោះ នោះសង្គមជាតិនឹងប្រឈមទៅនឹងភាពអនាធិបតេយ្យ អំពើអានាចារ ហើយសង្គមជាតិនឹងគ្មានភាពថ្លៃថ្នូរ។ ដូច្នេះការបង្កើតច្បាប់បទដ្ឋានមួយគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាសន្តិសុខ ឬសណ្តាប់ធ្នាប់សង្គម សម្រាប់ដោះស្រាយជម្លោះសម្រាប់ការពារសិទ្ធិមនុស្ស និងការសម្តែងឆន្ទៈរបស់រាស្ត្រ។ ជាមួយគ្នានេះដែរសម្រាប់ប្រទេសកម្ពុជាដែលកំពុងតែជួបនឹងវិបត្តិកូវីដ-១៩ ហើយបានវាយលុកយ៉ាងខ្លាំងទៅលើសុខភាពសាធារណៈ និងអ្វីដែលសំខាន់នោះគឺបញ្ហាសង្គម និងសេដ្ឋកិច្ច។ ម្ល៉ោះហើយទើបរាជរដ្ឋាភិបាលកម្ពុជាសម្រេចបង្កើតច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ដើម្បីគ្រប់គ្រង ក៏ដូចជាឆ្លើយតបទៅនឹងសភាពការណ៍។ ទន្ទឹមនឹងនេះក៏មាននៅវិធានការរឹតត្បិតសិទ្ធិផ្សេងរបស់ប្រជាពលរដ្ឋក្នុងកំឡុងពេលអនុវត្តច្បាប់ ដែលធ្វើឱ្យមានមតិមួយចំនួនមិនសូវពេញចិត្ត និងប្រឆាំងទៅនឹងច្បាប់មួយនេះទៀតផង។

ដូច្នេះ តើសិទ្ធិរបស់ប្រជាពលរដ្ឋអាចនឹងមានអ្វីកើតឡើងនៅពេលដែលច្បាប់នេះត្រូវបានអនុវត្ត? តើច្បាប់កូវីដ-១៩ រំលោភសិទ្ធិជាមូលដ្ឋាន និងដាក់ទោសធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋដែរឬទេ? ច្បាប់នេះទៀតសោត បានផ្តល់គុណប្រយោជន៍យ៉ាងណាចំពោះប្រទេស និងប្រជាជន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះមានគោលបំណងចំបង ក្នុងការផ្តល់នូវចំណេះដឹងទាក់ទិននឹងសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនខ្មែរ ក៏ដូចជាផ្តល់នូវចំណេះដឹងមួយចំនួនទាក់ទងនឹងសិទ្ធិនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មួយវិញទៀតក៏បានផ្តល់ចំណេះដឹង និងជួយវែកញែកពន្យល់ទៅលើច្បាប់បទដ្ឋានផ្សេងៗដូចជាច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ហើយអ្វីដែលពិសេសនោះគឺផ្តល់ចំណេះដឹងរវាងសិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងបរិបទច្បាប់ខាងលើនេះ។

## ៤. ទំហំ និងព្រំដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទស្តីពី "សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌច្បាប់កូវីដ-១៩" គឺជាការសិក្សាស្វែងយល់អំពីសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងសិទ្ធិជាមូលដ្ឋានរបស់

ប្រជាពលរដ្ឋនៅពេលដែលច្បាប់នេះបានចាប់ផ្តើមអនុវត្ត ហើយក៏ជាការសិក្សាស្វែងយល់ទំនាក់ទំនងរវាងច្បាប់កូវីដ-១៩ ជាមួយនឹងច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន ។

## ៥. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

អត្ថបទនៃកិច្ចការស្រាវជ្រាវអំពីប្រធានបទខាងលើត្រូវបានធ្វើការស្រាវជ្រាវ និងប្រមូលនូវទិន្នន័យដើម្បីបង្កើតនូវភាពច្បាស់លាស់ និងគុណភាពនៃការងារតាមរយៈវិធីសាស្ត្រមួយចំនួនដូចជា៖

- ការសង្កេតដោយផ្ទាល់នូវបរិយាកាសនៃការអនុវត្តន៍ច្បាប់
- ប្រើប្រាស់ទិន្នន័យដែលមានប្រភពមកពី៖ ច្បាប់លិខិតបទដ្ឋានគតិយុត្តិដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា
- ប្រភពឯកសារដែលបានធ្វើការស្រាវជ្រាវលើបណ្តាញអ៊ីនធឺណេត ឬគេហទំព័រ (Website) និងបណ្តាញសង្គមដែលសុទ្ធសឹងមានមូលដ្ឋានគ្រឹះរឹងមាំ និងមានភាពច្បាស់លាស់។

ម៉្យាងវិញទៀតចំពោះ ការប្រមូលព័ត៌មានគឺអនុវត្តទៅតាមដំណើរការនៃទិដ្ឋភាពជាក់ស្តែង និងតាមការសង្កេត ជាពិសេសគឺតាមរយៈការសាកសួរជាមួយ និស្សិត បុគ្គលិកដែលជាអ្នកធ្វើការ និងប្រជាជនដែលជាអ្នកប្រកបអាជីវកម្ម។

## ៦. អត្ថប្រយោជន៍នៃការស្រាវជ្រាវ

- ចំពោះនិស្សិត៖
  - អាចជួយឲ្យយល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ
  - អាចជួយឲ្យយល់ដឹងអំពីច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន និងច្បាប់កូវីដ១៩
  - បន្ថែមចំណេះដឹងមួយផ្នែកទៀតទាក់ទងទៅនឹងសិទ្ធជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងច្បាប់កូវីដ-១៩

- ចំពោះសង្គមជាតិ ៖
  - បង្ហាញពីគោលបំណងរបស់ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន
  - បង្ហាញពីសារៈសំខាន់ ក៏ដូចជាសារៈប្រយោជន៍របស់ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃ ជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ក្នុងការការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ វិស័យសង្គម និងសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។

➢ បង្ហាញអំពីសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

## ៧. រចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះត្រូវបានបែងចែកជា ៣ផ្នែកសំខាន់ៗ ដែលផ្នែកទី១ គឺជាសេចក្តីផ្តើម ផ្នែកទី២ គឺជាខ្លឹមសារនៃកិច្ចការស្រាវជ្រាវ និងផ្នែកទី៣ចុងក្រោយ គឺជាសេចក្តីសន្និដ្ឋានជារួម និងការចូលរួមផ្តល់អនុសាសន៍។

**១. សេចក្តីផ្តើម៖** នៅក្នុងផ្នែកទី១នៃអត្ថបទកិច្ចការស្រាវជ្រាវនេះគឺជា សេចក្តីផ្តើមដែលមានការលើកឡើងអំពីទិដ្ឋភាពទូទៅមកធ្វើការរៀបរាប់ ក៏ដូចជាលើកឡើងនូវលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ , ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ , វិធីសាស្រ្តនៃការស្រាវជ្រាវ , សារៈសំខាន់នៃការស្រាវជ្រាវ , និងរចនាសម្ព័ន្ធក្នុងកិច្ចការស្រាវជ្រាវ។

**២. ខ្លឹមសារនៃកិច្ចការស្រាវជ្រាវ៖** សម្រាប់ខ្លឹមសារតួសេចក្តីនៃកិច្ចការស្រាវជ្រាវនេះក៏បានបែងចែកជា ៤ ជំពូកដែលមានដូចតទៅ៖

ជំពូកទី១៖ លើកឡើងអំពីសិទ្ធិមនុស្ស ដែលមានសេចក្តីសង្ខេបសិទ្ធិទូទៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២៖ រៀបរាប់អំពីច្បាប់បទដ្ឋានផ្សេងដែលសម្រាប់ប្រើប្រាស់ក្នុងបរិបទកូវីដ-១៩ រួមមាន ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត និងទំនាក់ទំនងរវាងច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន និងច្បាប់កូវីដ-១៩។

ជំពូកទី៣៖ លើកឡើងអំពី ផលប៉ះពាល់លើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដែលរួមមាន : ការផ្តោតសំខាន់ទៅលើព័ត៌មានជាក់ស្តែងជុំវិញ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន និងច្បាប់កូវីដ-១៩, ទស្សនៈទានរបស់អង្គការសង្គមស៊ីវិលជុំវិញច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន និងច្បាប់កូវីដ-១៩, មតិមហាជនជាក់ស្តែងតាមរយៈបណ្តាញ សង្គមដែលមានមតិស្រប និងមតិមិនស្រប។

**៣. សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** ផ្នែកចុងក្រោយនៃកិច្ចការស្រាវជ្រាវនេះគឺជាសរុបសេចក្តីឡើងវិញ និងធ្វើការសន្និដ្ឋានដោយឆ្លើយតបទៅនឹងចំណោទបញ្ហានៃកិច្ចការស្រាវជ្រាវទាក់ទងទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌច្បាប់កូវីដ១៩ ព្រមទាំងការផ្តល់ជាមតិយោបល់ ឬអនុសាសន៍ផ្ទាល់ខ្លួនពាក់ព័ន្ធទៅនឹងប្រធានបទខាងដើមបន្ទាប់ពីបានឆ្លងកាត់នូវការស្រាវជ្រាវរួចមក។

# ជំពូកទី១
# ការសិក្សាអំពីទ្រឹស្តី

## ១.១. សេចក្តីផ្តើម

មនុស្សគ្រប់រូបដែលបានចាប់កំណើតកើតមកនៅក្នុងភពផែនដីយើងនេះគឺមានលក្ខណៈរួមមួយដែលដូចគ្នា នោះគឺភាពទទេរស្អាត។ នៅពេលដែលមនុស្សចាប់ផ្តើមធំពេញវ័យ គឺតែងតែមាននៅសម្បជញ្ញៈ ក្នុងការគិត ឬពិចារណា ទៅតាមសភាវៈរបស់ពួកគេ។ មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ។ សិទ្ធិ គឺជាគុណតម្លៃមួយរបស់មនុស្សក្នុងការប្រើប្រាស់ដើម្បី សម្រេច ការបញ្ចេញមតិ ការដើរដើរហើរ ការតវ៉ាប្រឆាំងទៅនឹងអ្វីដែលធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ខ្លួនឬគ្រួសារឬសហគមន៍ខ្លួន ការពារការរំលោភបំពានគ្រប់រូបភាពមកលើខ្លួនយើង និងអាទិភាពមួយចំនួនទៀតក្នុងការរស់នៅដើម្បីប្រកបដោយសេចក្តីថ្លៃថ្នូរ។ ដោយឡែកគោលការណ៍នៃសិទ្ធិមនុស្សជាសកល មនុស្សគ្រប់រូបមានសិទ្ធិស្មើៗគ្នា។ ដោយយល់ឃើញនូវគុណតម្លៃ និងសារៈសំខាន់អំពីសិទ្ធិបែបនេះហើយទើបប្រសូត្របាននូវសេចក្តីប្រកាសជាសកលមួយដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលសេចក្តីប្រកាសនោះឈ្មោះថា " **សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**"។ មហាសន្និបាត អ.ស.ប បានប្រកាសជាសាធារណៈថា សេចក្តីប្រកាសជាសកលនេះគឺជា "ឧត្តមគតិរួមដែល ប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឲ្យបានសម្រេច" [1] ។ សេចក្តីប្រកាសជាសកលនេះថែង អំពីទស្សនៈរួមមួយ ស្តីអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងឡាយ ដែលរដ្ឋជាសមាជិកបានប្តេជ្ញាចិត្ត អនុវត្តបញ្ញត្តិ នៃធម្មនុញ្ញសហប្រជាជាតិឲ្យបានសម្រេច។

## ១.២. និយមន័យសិទ្ធិ

ក. **សិទ្ធិ** សិទ្ធិគឺជាការទាមទារអំណាច ឬជាការប្រគល់អំណាចនូវអ្វីៗគ្រប់យ៉ាងដែលមនុស្សជឿថាគេត្រូវមាន និងគួរតែមាន [2] ។

[1] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្សប្រចាំកម្ពុជា, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ទំព័រ១, https://www.ohchr.org/EN/UDHR/Documents/UDHR_Translations/khm.pdf (ចូលទស្សនាថ្ងៃទី២០ សីហា ២០២១)។

[2] សាស្ត្រាចារ្យបណ្ឌិត ឈុន ណារ៉េត, សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ (ភ្នំពេញ៖ ផាងពុម្ភ ដារ៉ា , ២០១៦) ៣៦១។

ខ. សិទ្ធិមនុស្សត្រូវបានគេឲ្យនិយមន័យយ៉ាងសាមញ្ញថា : “ **សិទ្ធិមនុស្ស គឺជាអ្វីៗដែលសំខាន់ចាំបាច់សម្រាប់ការរស់រានមានជីវិតប្រកបដោយតម្លៃ និងសេចក្តីថ្លៃថ្នូរ ក្នុងភាពជាមនុស្ស** ” [3] ។

គ. **សិទ្ធិមនុស្ស** គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់ៗរូបដែលមានតាំងពីកំណើត ដើម្បីទាមទារនូវអ្វីៗធ្វើឲ្យមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ [4]។

## ១.៣. សារៈសំខាន់

មនុស្សខុសពីសត្វ ខុសពីរុក្ខជាតិ និងខុសពីធម្មជាតិផ្សេងៗ ជាពិសេសមនុស្សត្រូវមានមនសិការ មានវិចារណញ្ញាណ។ ដូច្នេះដើម្បីឲ្យមនុស្សរស់នៅប្រកបដោយមនសិការ វិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ ជាការចាំបាច់ដោយខានពុំបាន មនុស្សត្រូវតែមានសិទ្ធិ ហើយសិទ្ធិរបស់មនុស្សត្រូវតែបានគោរព។ មជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជាយល់ឃើញថាសិទ្ធិរបស់ប្រជាពលរដ្ឋជាប្រភពនៃអំណាចរបស់ប្រជាពលរដ្ឋ អំណាចរបស់ប្រជាពលរដ្ឋជាប្រភពនៃសុភមង្គលរបស់ប្រជាពលរដ្ឋ។ ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាននូវសុភមង្គលលុះត្រាតែប្រជាពលរដ្ឋមានសិទ្ធិ។ ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិទាំងនេះ លុះត្រាតែប្រជាពលរដ្ឋយល់អំពីសិទ្ធិ ហ៊ានអនុវត្តសិទ្ធិ ហើយរដ្ឋាភិបាលត្រូវគោរពសិទ្ធិ។ សារៈសំខាន់នៃសិទ្ធិមនុស្ស មានជាអាទិ៍[5]៖

១. ដើម្បីការពារជីវិតរស់នៅរបស់មនុស្ស

២. ដើម្បីទាមទារនូវសេចក្តីត្រូវការចាំបាច់របស់មនុស្ស

៣. ដើម្បីសេរីភាពរបស់មនុស្សក្នុងសង្គម

៤. ដើម្បីសេចក្តីសុខសន្តិភាព និងសុវត្ថិភាពរបស់មនុស្ស

៥. ដើម្បីសេចក្តីថ្លៃថ្នូររបស់មនុស្ស

៦. ដើម្បីការអភិវឌ្ឍន៍រីកចម្រើនក្នុងជីវភាពរស់នៅរបស់មនុស្ស

---

[3] សាស្ត្រាចារ្យបណ្ឌិត ឈុន ណារ៉េត, សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ (ភ្នំពេញៈ រោងពុម្ព ដារ៉ា , ២០១៦) ៣៦៦។

[4] ដូចខាងលើ។

[5] ដូចខាងលើ។

៧. ដើម្បីរស់នៅស្មើភាពគ្នាចំពោះមុខច្បាប់ និងចំពោះផលប្រយោជន៍នានាពីសង្គម។

## ១.៤. សិទ្ធិជាមូលដ្ឋាន

សិទ្ធិជាមូលដ្ឋានសំខាន់ៗរបស់មនុស្សត្រូវបានលើកឡើង ក្នុងកតិកាសញ្ញាអន្តរជាតិ និងបានបែងចែកសិទ្ធិមនុស្សជាមូលដ្ឋាន ៥ ផ្នែកសំខាន់ៗ ក្នុងនោះរួមមាន សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ [6] ។

- សិទ្ធិពលរដ្ឋ ៖ ពាក់ព័ន្ធនៃការរស់រានមានជីវិតរបស់បុគ្គល។
- សិទ្ធិនយោបាយ ៖ ពាក់ព័ន្ធនឹងការចូលរួមចំណែកក្នុងកិច្ចការនយោបាយ និងសង្គមជាតិ។
- សិទ្ធិសេដ្ឋកិច្ច ៖ ពាក់ព័ន្ធនឹងសន្តិសុខទ្រព្យសម្បត្តិ និងសុខមាលភាព។
- សិទ្ធិសង្គម ៖ ពាក់ព័ន្ធនឹងសិទ្ធិចូលរួមសម្ព័ន្ធនឹងគ្នាជាគ្រួសារតាមរយៈនៃការទទួលខុសត្រូវ និងការទទួលស្គាល់របស់សង្គម។
- សិទ្ធិវប្បធម៌ ៖ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការសម្តែងមនោសញ្ចេតនា ការប្រកាន់យកខាងផ្នែកវប្បធម៌តាមទ្រង់ទ្រាយច្រើនបែបច្រើនយ៉ាងរបស់សង្គម ដូចជា ភ្លេង របាំ សម្លៀកបំពាក់ និងភាសានៃវប្បធម៌ផ្សេងៗគ្នា។

សិទ្ធិមនុស្សជាមូលដ្ឋានដែលបានរៀបរាប់ទាំង ៥ ខាងលើនេះគឺត្រូវបានលើកឡើងក្នុងកតិកាសញ្ញាអន្តរជាតិ ហើយត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តនិងប្រកាសចូលជាធរមានដូចជា៖

- កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័ត កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងបានចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។
- កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តកាលពីថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងបានចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦។

[6] ការពិភាក្សាអំពីការអភិវឌ្ឍ, សិទ្ធិមនុស្សជាមូលដ្ឋាន, អាចរកបាននៅ https://www.facebook.com/notes/1057282551387196 (ចូលទស្សនាថ្ងៃទី ២០ សីហា ២០២១)។

ប្រទេសកម្ពុជាយើងក៏បានក្លាយជាសមាជិក ឬជារដ្ឋភាគីរបស់កតិកាសញ្ញាអន្តរជាតិខាងលើនេះផងដែរ។ ជាក់ស្តែងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ហើយបានផ្តលសច្ចាប័ននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ កតិកាសញ្ញានេះបានចូលជាធរមាននៅប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ ម្យ៉ាងវិញទៀតចំពោះកតិកាសញ្ញាស្តីពី សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ហើយបានផ្តល់សច្ចាប័ននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ កតិកាសញ្ញានេះបានចូលជាធរមាននៅប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ នៅពេលប្រទេសកម្ពុជា ក្លាយជាសមាជិក ឬជារដ្ឋភាគីរបស់កតិកាសញ្ញាអន្តរជាតិ ប្រទេសកម្ពុជាត្រូវតែគោរពប្រតិបត្តិតាមកតិកាសញ្ញានេះឲ្យបានល្អ ជាពិសេសបំពេញកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកាតិកាសញ្ញានេះ។

រហូតមកដល់ពេលនេះ ក្នុងការគោរពខ្លឹមសារនៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនៅកម្ពុជាយើងបានផ្តល់សច្ចាប័នទទួលស្គាល់កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិចំនួន ១១ [7] ។

### ១.៤.១. សិទ្ធិពលរដ្ឋ

**ក. សិទ្ធិរស់រានមានជីវិត** មនុស្សគ្រប់រូបត្រូវតែបានទទួលការការពារជីវិត និងមិនត្រូវឲ្យគេសម្លាប់ឡើយ។ ដើម្បីបំពេញលក្ខខណ្ឌនេះ រដ្ឋត្រូវធានាចរាចរឲ្យមានសណ្តាប់ធ្នាប់ មានសន្តិសុខ បញ្ចៀសសង្គ្រាម រំដោះមីន ឪសថមានគុណភាព ចំណីអាហារមិនហួសពេលវេលាកំណត់ និងគ្មានជាតិពុល ស្ពាន ថ្នល់មាំទាំ...។

**ខ.សិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរ** កើតមកដំបូងមនុស្សបរិសុទ្ធដូចគ្នា មានតម្លៃស្មើរគ្នា។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរដូចគ្នា ដោយគ្មានជនណាយកទៅធ្វើជាខ្ញុំកញ្ជះបង្ខូចកេរ្តិ៍ឈ្មោះ...។

**គ. សេរីភាពខាងជំនឿ និងមនសិការផ្ទាល់ខ្លួន** មនុស្សគ្រប់រូបអាចសម្រេចចិត្ត ដោយសេរីតាម សម្បជញ្ញៈផ្ទាល់ខ្លួន។ គេអាចជឿ ជ្រើសរើស ប្តូរសាសនា ឬបង្រៀនសាសនាដល់អ្នកដទៃ។

**ឃ. ឯកជនភាព ស្វ័យភាពផ្ទាល់ខ្លួន** គ្មានអ្នកណាបង្ខិតបង្ខំឲ្យគេផ្លាស់ប្តូររបៀបរស់នៅឡើយ បើគ្មានការយល់ព្រមពីសាមីខ្លួន។ មនុស្សគ្រប់រូមមានសិទ្ធិទៅរកច្បាប់ជួយការពារ បើមានការរំលោភ ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងអ្នកដ៏ទៃ។ ការចូលផ្ទះគេដោយគ្មានមូលហេតុ និងមិនបានប្រាប់មុខគឺជាការរំលោភ។

[7] សាស្ត្រាចារ្យបណ្ឌិត ឈុន ណារ៉េត, សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ (ភ្នំពេញ៖ ផាងពុម្ព ដារ៉ា , ២០១៦) ៣៦៨។

**ង. សេរីភាពក្នុងការបញ្ចេញមតិ និងចូលរួមក្នុងសហគមន៍** មនុស្សគ្រប់រូបមានសេរីភាពក្នុងការគិតគូរ សំដែងមតិ និងនិយាយស្តី។ គ្មានអ្នកណាឃាត់ឃាំងមិនឲ្យនិយាយស្តីបញ្ចេញយោបល់យកព័ត៌មាន ឬផ្តល់ព័ត៌មានតាមរយៈសៀវភៅ ការសែត វិទ្យុ ទូរទស្សន៍ ឬមធ្យោបាយផ្សេងៗទៀតឡើយ។

**ច. សិទ្ធិក្នុងការធ្វើដំណើរដោយសេរី** មនុស្សគ្រប់រូបមានសេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិតទូទាំងប្រទេស។ ក្នុងកាលៈទេសៈប្រទេសជាតិមានភាពអាសន្ន ជំងឺឆ្លង ជំងឺអាសន្នរោគជាដើម រដ្ឋមានចេញបម្រាមគោចរ ប៉ុន្តែបើចូលទៅប្រទេសដ៏ទៃត្រូវមានការអនុញ្ញាតពីប្រទេសនោះ។

**ឆ. សិទ្ធិទទួលបាននូវការការពារដោយច្បាប់** ច្បាប់សម្រាប់ការពារឲ្យមនុស្សទូទៅ។ អ្នកបំពានច្បាប់ រំលោភលើសិទ្ធិ ប៉ះពាល់ទ្រព្យសម្បត្តិកិត្តិយសរបស់យើង យើងត្រូវប្តឹងទៅតុលាការរកយុត្តិធម៌ទារជំងឺចិត្ត។

ការនិយមបក្សពួកជាការរំលោភច្បាប់។ អ្នកបំពានច្បាប់ត្រូវបានដាក់ទោសរដ្ឋអំណាច រំលោភពលរដ្ឋ ត្រូវសងជំងឺចិត្តអ្នករងគ្រោះ តុលាការកាត់ទោសដាក់ទណ្ឌកម្មផ្ទុយពីច្បាប់ ត្រូវទទួលកំហុស និងសងជំងឺចិត្ត។

ក្នុងប្រទេសប្រកាន់យករបបប្រជាធិបតេយ្យពិតប្រាកដ រដ្ឋាភិបាលដែលជាអ្នកអនុវត្តកម្មវិធីនយោបាយជាតិ ត្រូវគោរពអនុវត្តយ៉ាងម៉ឺងម៉ាត់គ្រប់ប្រការជំពូកនៃរដ្ឋធម្មនុញ្ញ។ រដ្ឋាភិបាលត្រូវដោះស្រាយគ្រប់សំណើ និងសំណូមពររបស់ប្រជាពលរដ្ឋ។ រដ្ឋាភិបាលត្រូវការប្រជាពលរដ្ឋឲ្យអនុវត្តសិទ្ធិរបស់ពួកគេ។ ឧទាហរណ៍ : ការសម្តែងមតិ ជាបាតុកម្ម កូដកម្ម ការតវ៉ាទាមទារអ្វីមួយដោយសន្តិវិធី រដ្ឋាភិបាលត្រូវមានភារកិច្ចការពារ តែមិនមែនប្រើមធ្យោបាយបង្ក្រាបឡើយ។

**ជ. សិទ្ធិទទួលនូវសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន** មនុស្សគ្រប់រូបមិនត្រូវបានគេចាប់ចងដោយរំលោភ ឬឃុំឃាំង។ ជនដែលត្រូវគេចាប់ខ្លួនមានសិទ្ធិទាមទារភ្លាមៗឲ្យគេបង្ហាញដីការចាប់ខ្លួន និងប្រាប់ហេតុផល និងប្រភេទនៃបទល្មើស។ ការចាប់ចងខុសច្បាប់ត្រូវប្តឹងទាមទារជម្ងឺចិត្ត។

### ១.៤.២. សិទ្ធិនយោបាយ

**ក. សិទ្ធិសេរីភាពក្នុងការនិយាយស្តី សារព័ត៌មាន ការប្រជុំ** ពលរដ្ឋគ្រប់រូបមានសេរីភាពពេញទីក្នុងការគិតគូរ សំដែងមតិ និងនិយាយស្តី។ ការឃាត់ឃាំងមិនឲ្យបញ្ចេញមតិ និយាយស្តី យកព័ត៌មាន ឬផ្តល់ព័ត៌មានតាមរយៈសៀវភៅ ការសែត វិទ្យុ ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗ គឺជាការរំលោភសិទ្ធិ។ ការប្រជុំរៀបចំធ្វើបាតុកម្មដោយសន្តិវិធី គឺជាសិទ្ធិពេញទីរបស់ពលរដ្ឋ។

**" ការហាមប្រជុំ ហាមធ្វើបាតុកម្មអហិង្សា គឺរំលោភសិទ្ធិ ការប្រើកម្លាំងអាវុធទៅបំបាត់បាតុករដែលគ្មានអាវុធ ដែលជារាសហាស្តូតគ្រង់ សិស្ស ឬនិស្សិត ជាការរំលោភសិទ្ធិមនុស្សផងដែរ"** ។ ការអនុវត្តសិទ្ធិសេរីភាពនេះ ត្រូវជៀសវៀងការប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។

**ខ. សិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត** ក្នុងប្រទេសប្រកាន់របបប្រជាធិបតេយ្យ ការបោះឆ្នោតមានសារៈសំខាន់ជាអាយុជីវិតជាតិក្នុងការជ្រើសរើស ផ្លាស់ប្តូរ អ្នកដឹកនាំ (មធ្យោបាយគ្មានការបង្ហូរឈាម) ។ ពលរដ្ឋខ្មែរគ្រប់អាយុបោះឆ្នោត ត្រូវប្រើសិទ្ធិឲ្យអស់លទ្ធភាព ដើម្បីសំដែងឆន្ទៈតាមមនសិការផ្ទាល់ខ្លួន។

**គ. សិទ្ធិចូលរួមបោះឆ្នោតដោយសេរី យុត្តិធម៌ និងទៀងទាត់** សិទ្ធិនេះត្រូវប្រជាពលរដ្ឋយកមកអនុវត្តតាមមនសិការឆន្ទៈផ្ទាល់ខ្លួន គ្មានការបង្ខិតបង្ខំគំរាមគំហែង ការទិញដូរ។ អាជ្ញាធររៀបចំការបោះឆ្នោតត្រូវតែឯករាជ្យ អព្យាក្រឹត្យ ឥតលំអៀង និងរៀបចណការបោះឆ្នោតតាមប្រតិទិនពេលវេលាទៀងទាត់ ពេលចប់អាណត្តិនីមួយៗ។ ការបោះឆ្នោតដែលស្របតាមលទ្ធិប្រជាធិបតេយ្យ ត្រូវគោរពតាមគោលការណ៍សំខាន់ៗ ៩ ចំណុចដូចខាងក្រោម៖

- គណៈកម្មាធិការ និងមន្ត្រីរៀបចំការបោះឆ្នោត ត្រូវតែឯករាជ្យ អព្យាក្រឹត្យ និងទទួលបាននូវការបណ្តុះបណ្តាលយ៉ាងល្អដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

- កិច្ចសង្កេតការណ៍ជាតិ និងអន្តរជាតិត្រូវមាននៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតហើយអង្គការក្រៅរដ្ឋាភិបាលអាចចូលរួមជាអ្នកបណ្តុះបណ្តាលអ្នកអង្កេតការណ៍ផងដែរ។

-ការបង្កើតឡើងនូវបរិយាកាសនយោបាយមួយប្រកបដោយសន្តិភាពសុវត្ថិភាព សេរីភាព និងយុត្តិធម៌សម្រាប់គ្រប់គណបក្សនយោបាយ បេក្ខជន និងអ្នកបោះឆ្នោត។

- រដ្ឋាភិបាល គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវតែគោរពសិទ្ធិមនុស្សយ៉ាងពេញលេញ។

-ការផ្តល់សិទ្ធិស្មើគ្នាចំពោះគ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មាន។ រីឯ ស្ថាប័ននិងសម្ភារៈរបស់រដ្ឋ មិនត្រូវយកទៅប្រើប្រាស់ជាផលប្រយោជន៍របស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។

- ការចុះឈ្មោះគណបក្សនយោបាយ និងបេក្ខជនត្រូវធ្វើដោយសេរី ហើយការចុះឈ្មោះអ្នកបោះឆ្នោត ត្រូវប្រព្រឹត្តទៅដោយឥតលំអៀង ស្របតាមនីតិវិធី និងច្បាប់។

- ដំណើរនៃយុទ្ធនាការនៃការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ នុងបេក្ខជនត្រូវធ្វើឡើងដោយសេរី ដោយមានការគោរពសេរីភាពក្នុងការចូលរួមប្រជុំ និងគាំទ្រការបញ្ចេញមតិ និងការប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោត។

- ការបោះឆ្នោតប្រព្រឹត្តទៅតាមការជ្រើសរើសដោយសេរី ដោយសម្ងាត់ ដោយគ្មានការបំភិតបំភ័យ ឬធ្វើទុក្ខបុកម្នេញ និងគ្មានវត្តមានកម្លាំងសន្តិសុខក្នុងបរិវេណនៃការិយាល័យបោះឆ្នោត។

- ហឹបឆ្នោត ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ត្រូវឲ្យមានការជឿទុកចិត្ត និងមានការទទួលស្គាល់។

**ឃ. សិទ្ធិបង្កើតសមាគម ឬគណបក្សនយោបាយ (សិទ្ធិធ្វើយុទ្ធនាការសម្រាប់គណបក្សនយោបាយ និងសិទ្ធិចូលរួមក្នុងគណបក្សនយោបាយ)**

- សិទ្ធិនេះត្រូវបានចែងយ៉ាងច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញមាត្រា ៤២ ។ រដ្ឋាភិបាលត្រូវបង្កលក្ខណៈងាយស្រួលដល់សមាគមន៍ គណបក្សនយោបាយក្នុងការធ្វើសកម្មភាពស្របច្បាប់របស់ពួកគេ។ ឧទាហរណ៍រដ្ឋបានគ្រប់ជាន់ថ្នាក់ត្រូវប្រកាន់ជំហរអព្យាក្រឹត្យ (បរិយាកាស នយោបាយ) បើកសិទ្ធិសេរីភាពស្របតាមច្បាប់ដល់គ្រប់គណបក្សនយោបាយ ក្នុងការធ្វើយុទ្ធនាការ ការចូលរួមប្រជុំ។ ជនណា ឬអាជ្ញាធរណាបំបិទសិទ្ធិសេរីភាពនេះ មានន័យថា ប្រឆាំងនឹងរដ្ឋធម្មនុញ្ញ។

**ង. សិទ្ធិមានលទ្ធភាពស្មើគ្នាក្នុងការចូលរួមបម្រើការងារសាធារណៈ (រួមទាំងសិទ្ធិទទួលការជ្រើសរើសឲ្យកាន់តំណែងការងារ**

ពលរដ្ឋគ្រប់រូប មានសិទ្ធិធ្វើការងារ ដើម្បីជីវភាពរស់នៅ។ ការជ្រើសរើសមុខរបរគឺជាសមត្ថភាព ជាជំនាញរបស់បុគ្គលម្នាក់ៗ។ រដ្ឋត្រូវបានធានាប្រាក់កម្រៃ គ្រប់គ្រាន់ និងសមរម្យ។ ជាការចាំបាច់ ពលរដ្ឋមានសិទ្ធិសុំប្រាក់ឧបត្ថម្ភពេលគ្មានការងារធ្វើ។ ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិទទួលបានប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ គេអាចបង្កើតសហជីព និងចូលរួមជាសមាជិកសហជីព។ ប្រទេសណាដែលមានប្រជាពលរដ្ឋភាគច្រើនឥតការងារធ្វើសេដ្ឋកិច្ចប្រទេសនេះមិនរីកចម្រើនឡើយ។

### ច. សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីក្នុងសកម្មភាពនយោបាយ

រដ្ឋធម្មនុញ្ញមាត្រា ៣៥ ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ និងមានសិទ្ធិចូលរួមក្នុងកិច្ចការរបស់ប្រទេសជាតិក្នុងសកម្មភាពផ្សេងៗរបស់រដ្ឋាភិបាល ដូចជាធ្វើជាអ្នករាជការ ទាហាន ឬនគរបាល ឬអាចឈរឈ្មោះជាតំណាងរាស្ត្រ។ ឧទាហរណ៍៖ ស្ត្រីជាអ្នកដឹកនាំនៅប្រទេសអង់គ្លេស បង់ក្លាដេស ប៉ាគីស្ថាន ហ្វីលីពីន ឥណ្ឌូនេស៊ី...។

### ១.៤.៣. សិទ្ធិសេដ្ឋកិច្ច

ទាក់ទងទៅនឹងសន្តិសុខទ្រព្យសម្បត្តិ និងសុខមាលភាព។ ដូចជាសិទ្ធិធ្វើការងារ គឺជាសិទ្ធិរបស់ជនគ្រប់រូបក្នុងការមានឱកាសបង្កើនជីវភាពរស់នៅរបស់ខ្លួន ដោយសារការធ្វើការងារតាមការជ្រើសរើសរបស់ខ្លួន ឬតាមការយល់ព្រមយក ហើយរដ្ឋាភិបាលដែលគាំទ្រប្រព័ន្ធសេដ្ឋកិច្ចមួយ ត្រូវផ្តល់ឱកាសឲ្យច្រើនល្អប្រសើរ និងផ្តល់ឲ្យមានកម្មវិធីនានា ដូចជាកម្មវិធីហ្វឹកហ្វឺនវិជ្ជាជីវៈជាដើម។ សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារដែលអាចទទួលយកបាន សិទ្ធិបង្កើតសហជីពឯករាជ្យ សិទ្ធិធ្វើកូដកម្ម សិទ្ធិមានផ្ទះសម្បែងស្នាក់នៅសមរម្យ។ ល។

### ១.៤.៤. សិទ្ធិសង្គម

ទាក់ទងទៅនឹងសិទ្ធិចូលរួមសម្ព័ន្ធនិងគ្នាជាគ្រួសារ តាមរយៈនៃការទទួលខុសត្រូវ និងការទទួលស្គាល់របស់សង្គម។ ដូចជា សិទ្ធិមានគ្រួសារ សិទ្ធិរៀបអាពាហ៍ពិពាហ៍ សិទ្ធិទទួលបាននូវការថែទាំសុខភាព និងសិទ្ធិទទួលបានការអប់រំគ្រប់គ្រាន់។ល។

### ១.៤.៥. សិទ្ធិវប្បធម៌

ទាក់ទងទៅនឹងសិទ្ធិសំដែងមនោសញ្ចេតនា ការប្រកាន់យកផ្នែកវប្បធម៌តាមទ្រង់ទ្រាយច្រើនបែបច្រើនយ៉ាងរបស់សង្គម។ ដូចជាភ្លេង របាំ សំលៀកបំពាក់ និងភាសានៃវប្បធម៌ផ្សេងៗគ្នា។ល។

សិទ្ធិទាំងនោះត្រូវបែងចែកជាពីរជំពូកធំៗ ដូចខាងក្រោម [8] ៖

- សិទ្ធិពលរដ្ឋ និង នយោបាយមានជាអាទិ៍៖
  - សិទ្ធិរស់រានមានជីវិត

[8] សាស្ត្រាចារ្យបណ្ឌិត ឈុន ណារ៉េត, សៀវភៅសេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ (ភ្នំពេញ៖ ផាងពុម្ព ដារ៉ា , ២០១៦) ៣៧៥។

- ○ សិទ្ធិគ្មានការរើសអើង
- ○ សិទ្ធិមិនទទួលការចាប់ខ្លួន ឃុំខ្លួនតាមអំពើចិត្ត
- ○ សិទ្ធិសេរីភាពក្នុងការដើរហើរ
- ○ សិទ្ធិមិនទទួលរងការធ្វើទារុណកម្ម
- ○ សិទ្ធិមានការប្រជុំដោយសន្តិវិធី
- ○ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ
- ○ សិទ្ធិចង្កើតគណបក្សនយោបាយ
- ○ សិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជន
- ○ សេរីភាពក្នុងការតាំងទីលំនៅ
- ○ សិទ្ធិមានកម្មសិទ្ធិ

▪ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌មានជាអាទិ៍៖

- ○ សិទ្ធិមានចំណីអាហារហូបគ្រប់គ្រាន់
- ○ សិទ្ធិទទួលបាននូវលក្ខខណ្ឌរស់នៅសមរម្យ
- ○ សិទ្ធិមានការគាំពារខាងសុខភាព
- ○ សិទ្ធិមានផ្ទះសម្បែង និងកម្មសិទ្ធិដីធ្លី
- ○ សិទ្ធិទទួលបានការអប់រំ
- ○ សិទ្ធិមានការងារធ្វើ
- ○ សិទ្ធិមានប្រាក់កម្រៃគ្នាចំពោះការងារដូចគ្នា
- ○ សិទ្ធិមិនរងការបង្ខិតបង្ខំឲ្យធ្វើការហួសកំលាំង
- ○ សិទ្ធិបង្កើតសហជីព
- ○ សិទ្ធិសម្រាកលំហែកវិស្សមកាល ឬមាតុភាព

- សិទ្ធិសម្តែងសិល្បៈវប្បធម៌

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសិទ្ធសេដ្ឋកិច្ច សង្គម និងវប្បធម៌ មានសារៈសំខាន់ដូចគ្នា និងមិនអាចកាត់ផ្តាច់ចេញពីគ្នាបានទេ។ ដូច្នេះយើងមិនអាចនិយាយថា សិទ្ធិពលរដ្ឋ និងនយោបាយ មានភាពប្រសើរជាងសីទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នោះដែរ ព្រោះថាសិទ្ធិជាមូលដ្ឋានទាំង ៥ នេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយថែមទាំងបានជួយគាំទ្រគ្នាទៅវិញទៅមក។

## ១.៥. ច្បាប់ សិទ្ធិ សេរីភាព និងករណីយកិច្ច

ដើម្បីជាពុទ្ធិ និងមិនឲ្យមានការភ័ន្តច្រឡំរវាង ច្បាប់ សិទ្ធិ សេរីភាព និងករណីកិច្ច បុគ្គលគ្រប់រូបគួរគប្បីយល់ឱ្យបានច្បាស់នូវអត្ថន័យនៃពាក្យនីមួយៗ ព្រោះជារឿងចាំបាច់ ហើយការគោរពប្រតិបត្តិសិទ្ធិមនុស្សបានល្អក៏អាស្រ័យដោយតួអង្គសង្គមទាំងអស់បំពេញកាតព្វកិច្ច និងករណីកិច្ចបានត្រឹមត្រូវ ។ ម្ល៉ោះហើយយើងគួរស្វែងយល់ពាក្យនីមួយឲ្យបានច្បាស់ ចៀសវាងនូវការប្រើប្រាស់ដោយភ័ន្តច្រឡំ ឬរំលោភដល់សិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ ឬរំលោភច្បាប់របស់រដ្ឋ ឬប្រទេសនីមួយៗ [9]។

**ច្បាប់** គឺជាសំណុំវិធានទាំងអស់ដែលត្រូវបានបង្កើតឡើងដោយរដ្ឋ និងអនុវត្តដោយរដ្ឋ ក្នុងគោលដៅគ្រប់គ្រងដោយកំណត់នូវរបៀបដែលស្ថាប័នរដ្ឋត្រូវប្រតិបត្តិ និងកម្រិតនូវទង្វើរបស់មនុស្សក្នុងសង្គម។ ជាមួយគ្នានេះដែរច្បាប់មានមុខងារចម្បង ៤ យ៉ាងគឺ [10]៖

- ទី១ ច្បាប់ជាវិធានដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។ អ្នកគ្រប់គ្រងរដ្ឋបានបង្កើតច្បាប់ និងអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង ដើម្បីធានាបាននូវរបៀបរៀបរយ និងស្ថេរភាពសង្គម។ ក៏ប៉ុន្តែ ក៏ត្រូវគិតគូរអំពីសិទ្ធិសេរីភាពរបស់មនុស្សផងដែរ។ មនុស្សអាចនឹងមិនសប្បាយចិត្ត ប្រសិនបើយកការអនុវត្តច្បាប់មកគាបសង្កត់សេរីភាពពួកគេ។

[9] ការពិភាក្សាអំពីការអភិវឌ្ឍ, សិទ្ធិមនុស្សជាមូលដ្ឋាន, អាចរកបាននៅ https://www.facebook.com/notes/1057282551387196 (ចូលទស្សនាថ្ងៃទី ២០ សីហា ២០២១)។

[10] ច្បាប់ ព័ត៌មាន ចំណេះដឹង ,ច្បាប់ជាអ្វី? មានមុខងារអ្វីខ្លះ? មានសារៈសំខាន់យ៉ាងដូចម្តេច?, អាចរកបាននៅ https://www.facebook.com/109495307133474/photos/a.109498897133115/410892950327040/ (ចូលទស្សនាថ្ងៃទី ២០ សីហា ២០២១)។

- ទី២ ច្បាប់ជាវិធានសម្រាប់ដោះស្រាយជម្លោះ។ ដោយផ្អែកលើគោលការណ៍សមធម៌ ច្បាប់ត្រូវបានបង្កើតឡើងដើម្បីបែងចែកឲ្យមនុស្សទទួលបានផលស្មើៗគ្នា ដើម្បីជៀសវាងការកើតជម្លោះ ដែលជាហេតុនាំឲ្យមានសន្តិភាពនៅក្នុងសង្គម។
- ទី៣ ច្បាប់ជាវិធានសម្រាប់ការពារសិទ្ធិមនុស្ស។ ក្រោយមានការកើតសង្គ្រាមវិនាសព្រាត់ប្រាស និងការរំលោភសិទ្ធិមនុស្សក៏គួឲ្យភ័យខ្លាចនៅក្នុងប្រទេសកម្ពុជាកន្លងទៅ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ និងជាលើកទី១ដែលរដ្ឋសភាកម្ពុជា បាន បញ្ចូលច្បាប់សិទ្ធិមនុស្សអន្តរជាតិនានាទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា គឺជាការបានបំពេញបំណងប្រាថ្នារបស់ប្រជារាស្ត្រខ្មែរ ដែលចង់បានច្បាប់បញ្ជាក់នូវការគោរពសិទ្ធិមនុស្ស។
- ទី៤ ច្បាប់ជាការសម្តែងឆន្ទៈរបស់រាស្ត្រ។ ដោយសារតែប្រជារាស្ត្រមានគ្នាច្រើន មិនអាចមកជួបជុំគ្នាបានក្នុងពេលតែមួយ ទើបមានការរៀបចំបោះឆ្នោតដើម្បីឲ្យរាស្ត្របានជ្រើសរើសតំណាងរបស់ខ្លួនដែលហៅថាតំណាងរាស្ត្រ ឲ្យទៅជួបជុំគ្នាធ្វើការងារ មានការងារធ្វើច្បាប់ និងការងារតាមដានសកម្មភាពរបស់រដ្ឋាភិបាលជាដើម ។

**សិទ្ធិ** គឺ អ្វីៗដែលមនុស្សត្រូវតែមានជាចាំបាច់ដើម្បីរស់ឱ្យសមរម្យជាមនុស្ស។

សិទ្ធិ គឺជាអំណាចដែលត្រូវបានទទួលស្គាល់ត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចទទួលនូវការការពារ ឬទាមទារនូវការផលប្រយោជន៍ ដែលបានកំណត់ ។ សិទ្ធិ អាចសំដៅទៅអ្វីៗទាំងឡាយដែលជាសេរីភាពស្របច្បាប់ ឬការអនុញ្ញាតដោយច្បាប់ សង្គម និងក្រមសីលធម៌ ។ មនុស្សគ្រប់រូបត្រូវបានទទួលស្គាល់សិទ្ធិទាំងអស់ដូចមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ សិទ្ធិមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសតាមបរិបទនៃប្រពៃណី ការសន្មត់របស់សង្គម ឬច្បាប់ប្រទេស ហើយកត្តាទាំងអស់នេះហើយបានកម្រិតនូវសិទ្ធិសេរីភាពរបស់មនុស្ស [11]។

ផ្ទុយទៅវិញ ការប្រើសិទ្ធិ ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ការប្រើប្រាស់សិទ្ធិនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

[11] ការពិភាក្សាអំពីការអភិវឌ្ឍ, សិទ្ធិមនុស្សជាមូលដ្ឋាន, អាចរកបាននៅ https://www.facebook.com/notes/1057282551387196 (ចូលទស្សនាថ្ងៃទី ២០ សីហា ២០២១)។

**សេរីភាព** គឺអំណាចរបស់បុគ្គលម្នាក់ដែលធ្វើអ្វីដោយសេរីមិនចាំបាច់មានការអនុញ្ញាត ។ សេរីភាព មិនមានដែនកំណត់ទេ ប៉ុន្តែនៅក្នុងសង្គមមួយចំនួនទៀត សេរីភាព ត្រូវបានកម្រិតដោយច្បាប់ ឬអំណាចរបស់រដ្ឋក្នុងការអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើអ្វីមួយបាន ឬមិនអាចធ្វើអ្វីបាន ។

ផ្ទុយទៅវិញ ការប្រើសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ការប្រើប្រាស់សេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**ករណីយកិច្ច** ករណីយកិច្ចសំខាន់ៗរបស់ប្រជាពលរដ្ឋត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូល ។ នៅក្នុងជំពូកទី៣ និយាយអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ។

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពសេរីភាពរបស់អ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

# ជំពូកទី២
# ច្បាប់បទដ្ឋានផ្សេងៗដែលពាក់ព័ន្ធក្នុងបរិបទកូវីដ-១៩

## ២.១. រំលឹកអំពីសាវតានៃជំងឺកូវីដ-១៩

វីរុសកូរ៉ូណាប្រភេទថ្មី (CoV) គឺជាវីរុសថ្មីនៃអម្បូរវីរុសកូរ៉ូណា ត្រូវបានគេរកឃើញដំបូងក្នុងខែធ្នូ ឆ្នាំ២០១៩ នៅក្នុងទីក្រុងវូហាន ខេត្តហ៊ូប៉ីរបស់ប្រទេសចិន។ ដែលត្រូវបានគេដាក់ឈ្មោះថា **ជំងឺវីរុសកូរ៉ូណាឆ្នាំ ២០១៩** (កូវីដ១៩/COVID-19) ដែលពាក្យកាត់ "CO" តំណាងឱ្យពាក្យ corona (កូរ៉ូណា) "VI" តំណាងឱ្យពាក្យ virus (វីរុស) និង "D" តំណាងឱ្យពាក្យ disease (ជំងឺ)។ កាលពីមុន ជំងឺនេះត្រូវបានគេហៅឈ្មោះថា "វីរុសកូរ៉ូណាប្រភេទថ្មីឆ្នាំ២០១៩" ឬ "2019-nCoV" [12]។

វីរុស COVID-19 (កូវីដ-១៩) គឺជាវីរុសថ្មីមួយដែលមានទំនាក់ទំនងទៅនឹងអម្បូរនៃវីរុសដូចគ្នានឹងជម្ងឺរោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ (SARS) និងប្រភេទជំងឺផ្តាសាយទូទៅមួយចំនួនទៀត។ វីរុសនេះត្រូវបានចម្លងតាមរយៈការប៉ះពាល់ផ្ទាល់ទៅនឹងដំណក់ទឹកតូចៗដែលចេញពីប្រព័ន្ធផ្លូវដង្ហើមរបស់អ្នកដែលបានឆ្លងវីរុស (តាមរយៈការក្អក និងកណ្តាស់) និងការប៉ះទៅលើផ្ទៃនានាមានវីរុស។ វីរុស COVID-19 (កូវីដ-១៩) អាចរស់នៅផ្ទៃខាងក្រៅបានជាច្រើនម៉ោង ប៉ុន្តែថ្នាំសម្លាប់វីរុសទូទៅអាចប្រើដើម្បីសម្លាប់វាបាន។

រោគសញ្ញាអាចជាគ្រុនក្តៅ ក្អក និងថប់ដង្ហើម។ ក្នុងករណីធ្ងន់ធ្ងរជាងនេះ ការឆ្លងវីរុសនេះអាចបណ្តាលឱ្យកើតជំងឺរលាកសួត ឬពិបាកដកដង្ហើម និងអាចបណ្តាលឱ្យស្លាប់បាន។ រោគសញ្ញាទាំងនេះស្រដៀងនឹងជំងឺ

---

[12] អង្គការយូនីសេហ្វ, វីរុសកូរ៉ូណា (កូវីដ-១៩/ COVID-19)៖ ចំណេះដឹងឪពុកម្តាយគួរស្វែងយល់ , អាចរកបាននៅ https://www.unicef.org/cambodia/km/%E1%9E%9C%E1%9E%B8%E1%9E%9A%E1%9E%BB%E1%9E%9F%E1%9E%80%E1%9E%BC%E1%9E%9A%E1%9F%89%E1%9E%BC%E1%9E%8E%E1%9E%B6-%E1%9E%80%E1%9E%BC%E1%9E%9C%E1%9E%B8%E1%9E%8A%E1%9F%A1%E1%9F%A9-covid-19%E1%9F%96-%E1%9E%85%E1%9F%86%E1%9E%8E%E1%9F%81%E1%9F%87%E1%9E%8A%E1%9E%B9%E1%9E%84%E1%9E%AA%E1%9E%96%E1%9E%BB%E1%9E%80%E1%9E%98%E1%9F%92%E1%9E%8F%E1%9E%B6%E1%9E%99%E1%9E%82%E1%9E%BD%E1%9E%9A%E1%9E%9F%E1%9F%92%E1%9E%9C%E1%9F%82%E1%9E%84%E1%9E%99%E1%9E%9B%E1%9F%8B (ចូលទស្សនាថ្ងៃទី ២១ សីហា ២០២១)។

ផ្តាសាយ (influenza) ឬ ជំងឺផ្តាសាយទូទៅដែលកើតមានច្រើនជាង COVID-19 (កូវីដ-១៩) ។ នេះជាមូលហេតុដែលតម្រូវឱ្យមានការធ្វើតេស្តដើម្បីបញ្ជាក់ថា អ្នកណាម្នាក់ពិតជាមានផ្ទុកវីរុស COVID-19 (កូវីដ-១៩) ។ វាជាការសំខាន់ដែលត្រូវចងចាំថា វិធានការការពារសំខាន់ៗគឺមានលក្ខណៈដូចគ្នាដូចជាលាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹក ឬប្រើអាកុល និងដែលជាដើម។ រក្សាអនាម័យផ្លូវដង្ហើម (ខ្ទប់មាត់នៅពេលក្អក ឬកណ្តាស់ ដោយប្រើកែងដៃ ឬក្រដាសជូតមាត់ និងបន្ទាប់មកបោះចោលក្រដាសជូតមាត់ក្នុងធុងសំរាមបិទជិត) និង ពាក់ម៉ាស។

## ២.២. ការឆ្លងចូលនៃជំងឺកូវីដ-១៩មកក្នុងព្រះរាជាណាចក្រកម្ពុជា

ខណៈដែលការរីករាលដាលនៃជំងឺកូវីដ-១៩ ទៅជុំវិញពិភពលោក បន្តក្លាយជាជំងឺរាត្បាតសកលប្រទេសកម្ពុជាសឹងតែពេញមួយឆ្នាំ នៅក្នុងឆ្នាំ២០២០ មានការទប់ស្កាត់ ឬប្រយុទ្ធប្រឆាំងនៃជំងឺកូវីដ-១៩ បានល្អ។ ប៉ុន្តែនៅរយៈពេលចុងឆ្នាំ២០២០ ប្រទេសកម្ពុជាមានការឆ្លងចូលនៃជំងឺកូវីដ-១៩នេះ រហូតដល់ទៅពីរលើកដែលត្រូវបានគេហៅថា ព្រឹត្តិការណ៍ ៣ វិច្ឆិកា និង ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា។

**ព្រឹត្តិការណ៍ ០៣វិច្ឆិកា** គឺជាការឆ្លងនៃជំងឺកូវីដ-១៩ ចូលមកក្នុងប្រទេសដែលគ្រានោះ គឺជាការបំពេញទស្សនៈកិច្ចរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មហុងគ្រី មកកាន់ប្រទេសកម្ពុជាចំនួនមួយថ្ងៃ គឺនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។ លោករដ្ឋមន្ត្រីការបរទេសហុងគ្រី ភីធី ស៊ីចាតូ បានបញ្ចប់ការទស្សនៈកិច្ច និងចាកចេញពីប្រទេសកម្ពុជានៅល្ងាចថ្ងៃទី០៣ ខែវិច្ឆិកា ហើយត្រូវធ្វើដំណើរបន្តទៅកាន់ប្រទេសថៃ ក៏ប៉ុន្តែត្រូវបានលុបចោលភ្លាមៗបន្ទាប់ពីរកឃើញថាមានវិជ្ជមានកូវីដ -១៩។ រូបលោក និងគណៈប្រតិភូដ៏ទៃទៀតត្រូវបានបញ្ជូនទៅប្រទេសហុងគ្រីវិញដោយយន្តហោះឯកជន ដែលរៀបចំដោយរដ្ឋាភិបាលហុងគ្រី [13] ។ បើតាមសារព័ត៌មានរបស់វិទ្យុបារាំងដែលផ្សាយជាភាសាខ្មែរ ឬហៅថា (RFI) បានលើកឡើងទៀតដែរថា ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជា លោក ភីធើ ស៊ីចាតូ បានជួបពិភាក្សាការងារជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង

[13] វណ្ណ សុគន្ធា, “ ក្រសួងសុខាភិបាលៈអ្នកប៉ះពាល់ជាមួយរដ្ឋមន្ត្រីការបរទេសហុងគ្រីមាន៦២៨នាក់ ប៉ុន្តែសុទ្ធតែតេស្តអវិជ្ជមានទាំងអស់ ” , rfi , ០៥ វិច្ឆិកា ២០២០,អាចរកបាននៅ https://www.rfi.fr/km/%E1%9E%80%E1%9E%98%E1%9F%92%E1%9E%96%E1%9E%BB%E1%9E%87%E1%9E%B6/20201105 (ចូលទស្សនាថ្ងៃទី២១ សីហា ២០២១)។

មន្ត្រីជាន់ខ្ពស់កម្ពុជាជាច្រើនរូបទៀត ក្នុងនោះមាន រដ្ឋមន្ត្រីក្រសួងកសិកម្ម , រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម មន្ត្រីតំណាងរាស្ត្រ និងអង្គរក្ស អ្នករៀបចំកម្មវិធីមួយចំនួនទៀត ។

បន្ទាប់ពីរដ្ឋមន្ត្រីហុងគ្រីរកឃើញមានផ្ទុកជំងឺកូវីដ-១៩នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចឱ្យថ្នាក់ដឹកនាំផ្សេងៗ និងមន្ត្រីទាំងអស់ដែលបានជួប និង ប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រតិភូហុងគ្រីធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃតាមកំណត់របស់ក្រសួងសុខាភិបាល។ ចំណែក សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន វិញ ក៏បានដាក់ខ្លួនឯងឱ្យដាច់ដោយឡែកពីគេផងដែរ ហើយថែមទាំងលុបចោលនូវកម្មវិធីមួយចំនួនទៀតផង ។

**ព្រឹត្តិការណ៍ឆ្លងចូលសហគមន៍ ២៨វិច្ឆិកា** គឺជាករណីមួយដែលបានកើតឡើងបន្ទាប់ពីរកឃើញស្ត្រីជនជាតិខ្មែរវ័យចំណាស់ម្នាក់បានផ្ទុកជំងឺកូវីដ-១៩ ហើយមិនដឹងប្រភពថាឆ្លងមកពីណា។ ស្ត្រីវ័យចំណាស់រូបនោះត្រូវបានគេស្គាល់ថាជាភរិយារបស់លោកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគា ហើយក្រោយមកទៀតក៏បានរកឃើញនូវអ្នកពាក់ព័ន្ធជាច្រើនអ្នកផ្សេងទៀត ដែលធ្វើឲ្យរាជរដ្ឋាភិបាលមានការព្រួយបារម្ភយ៉ាងខ្លាំង។ បើតាមសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីករណីវិជ្ជមានវីរុសកូវីដ-១៩ ត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២០ មានចំនួនសរុប ៣២៦នាក់ [14] ។

មុននឹងបង្កើតបាននូវច្បាប់ប្រឆាំងកូវីដ-១៩ ដាច់ដោយឡែកនេះ ប្រទេសកម្ពុជាក៏បានបង្កើតនូវច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្នរួចរាល់ជាស្រេចហើយកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ននេះមានភាពអនុលោមទៅនឹងរដ្ឋធម្មនុញ្ញដូចដែលមានចែងនៅក្នុងមាត្រា២២ ថា នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ ក៏ប៉ុន្តែ មូលហេតុផ្សេងៗដែលរាជរដ្ឋាភិបាលបានលើកឡើងអំពីការមិនអនុវត្តនូវច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងគ្រាអាសន្ននេះគឺ មហន្តរាយផ្នែកសេដ្ឋកិច្ច ប៉ះពាល់សិទ្ធិសេរីភាពរបស់បុគ្គលខ្លាំង។ ហេតុនេះហើយទើបមកដល់ពេលនេះកម្ពុជាត្រូវការច្បាប់ពិសេសនិងដាច់ដោយឡែកមួយសម្រាប់គ្រប់គ្រងទៅនឹងសភាពការណ៍ដែលបានកើតឡើងក្នុងពេលបច្ចុប្បន្ន។ ជាមួយគ្នានេះដែរ ឯកឧត្តម

---

[14] TR110, “ ក្រសួងសុខាភិបាល រកឃើញអ្នកឆ្លងកូវីដ១៩ថ្មី៣នាក់ ពាក់ព័ន្ធព្រឹត្តិការណ៍ សហគមន៍២៨វិច្ឆិកា និងជាសះស្បើយ៣នាក់ ”, ដើមអម្ពិល DAP NEWS, ០១ ធ្នូ ២០២០,អាចរកបាននៅ https://dap-news.com/national/2020/12/01/102290/ (ចូលទស្សនាថ្ងៃទី២១ សីហា ២០២១)។

កើត រិទ្ធ ក៏បានលើកឡើងនូវមូលហេតុដែលមិនប្រើច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងគ្រាអាសន្នផងដែរថា " នៅពេលដែលជំងឺនេះបានឆ្លងចូលមកដល់កម្ពុជាភ្លាម រាជរដ្ឋាភិបាលជាមួយនឹងស្មារតីបុរេសកម្ម ត្រៀមលក្ខណៈម្ចាស់ការគឺយើងបានរៀបចំនូវច្បាប់គ្រាអសន្នដែលផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយសារបណ្តាប្រទេសផ្សេងគេច្បាប់ផ្តើមដាក់ច្បាប់គ្រាអសន្នរបស់គេប្រើ ឯកម្ពុជាមិនទាន់មាននៅពេលនោះ អញ្ចឹងក្នុងខែមេសា ឆ្នាំ២០២០ យើងសម្រេចបាននូវច្បាប់គ្រាអសន្នមួយ។ ប៉ុន្តែជាបទពិសោធន៍នៃការគ្រប់គ្រងនូវជំងឺកូវីដរយៈពេលជាងមួយឆ្នាំនៅកម្ពុជា និងបទពិសោធន៍នៃការគ្រប់គ្រង ឬក៏ការប្រយុទ្ធប្រឆាំងនឹងការឆ្លងរាលដាលនៃជំងឺកូវីដនេះនៅក្នុងពិភពលោក ការប្រើប្រាស់ច្បាប់គ្រាអសន្នមិនប្រាកដថាអាចធ្វើឲ្យស្ថានភាពនោះថមថយទៅវិញបានទេ។

បន្ថែមពីនោះ ចំណុចសំខាន់មួយដែលចេញពីការប្រើប្រាស់ច្បាប់គ្រាអសន្ន គឺបង្កើតឲ្យមានមហន្តរាយផ្នែកសេដ្ឋកិច្ច ឬស្នះសសៃឈាមសេដ្ឋកិច្ចតែម្តង។ ក្នុងពេលដែលប្រឈមទៅនឹងវិបត្តិសង្គមផ្នែកសុខភាពសាធារណៈ អាយុជីវិតប្រជាជនត្រូវបានបាត់បង់ ទន្ទឹមនឹងនេះបង្កើតបាននូវមហន្តរាយមួយទៀតផ្នែកសេដ្ឋកិច្ចនៅក្នុងសង្គមនៅក្នុងបណ្តាប្រទេសជាច្រើន។ កម្ពុជាដោយសម្លឹងមើលឃើញអំពីផលវិបាកទាក់ទងនឹងការប្រើប្រាស់ច្បាប់គ្រាអាសន្ននេះ ដូច្នេះសម្តេចតេជោនាយករដ្ឋមន្រ្តី បានធ្វើការសម្រេចថានឹងមិនប្រើច្បាប់គ្រាអាសន្នសម្រាប់បញ្ហាកូវីដនៅកម្ពុជាទេ។ នេះជាចំណុចទីមួយ ហើយចំណុចទីពីរ អ្វីដែរគួរឲ្យកត់សម្គាល់នោះថាអ្វីដែលជាការគ្រប់គ្រង និងជាការដឹកនាំក្នុងរយៈពេលជាងមួយឆ្នាំនេះយើងឆ្លងកាត់នូវបទពិសោធន៍មួយថាមកដល់ម៉ោងនេះត្រូវមានច្បាប់ ជាពិសេសគឺការលេចចេញនូវព្រឹត្តិការណ៍ ២០កម្ភៈ គឺកម្ពុជាបានពិនិត្យមើលនៅស្ថានភាពច្បាប់បច្ចុប្បន្នរបស់ខ្លួន ក្នុងពេលដែលយើងមិនអាចប្រើប្រាស់នូវច្បាប់គ្រាអាសន្ន គឺត្រូវច្បាប់បទដ្ឋានគតិយុត្តិមួយរឹងមាំដើម្បីអាចគ្រប់គ្រងបាន [15] ។"

ដូច្នេះដោយសារតែមើលឃើញអំពីបញ្ហាទាំងនេះហើយទើបកម្ពុជាបានបង្កើតនូវច្បាប់បទដ្ឋានគតិយុត្តិថ្មីមួយទៀតសម្រាប់ជំនួសឲ្យច្បាប់គ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន។

## ២.៣. ច្បាប់ប្រឆាំងកូវីដ-១៩

ច្បាប់កូវីដ-១៩ គឺជាឈ្មោះហៅកាត់បែបខ្លីមួយសម្រាប់ងាយស្រួលក្នុងការហៅ ចំណែកឈ្មោះពេញនៃច្បាប់មួយនេះគឺ "ច្បាប់ស្តីពីវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងជម្ងឺឆ្លងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត" ។ ច្បាប់នេះទៀតសោតត្រូវបានបង្កើតឡើងកំឡុងខែមីនា ឆ្នាំ២០២១ ដើម្បីឆ្លើយតប

[15] ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, មូលហេតុនៃការបង្កើតច្បាប់កូវីដ, អាចរកបាននៅ https://www.youtube.com/watch?v=uiRsh97YLtU , (ចូលទស្សនានៅថ្ងៃទី ២២ សីហា ២០២១)។

ទៅនឹងសភាពការណ៍ដែលប្រទេសកំពុងជួបនូវបញ្ហាខ្លាំង នោះគឺជំងឺកូវីដ-១៩។ មួយវិញទៀតដោយសារតែកើតមាននូវព្រឹត្តិការណ៍២០កុម្ភៈ ទើបជម្រុញឲ្យមានច្បាប់ពិសេសមួយនេះ ជំនួសឲ្យច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន [16]។ ជាមួយគ្នានេះដែរការបង្កើតច្បាប់កូវីដ-១៩នេះឡើងគឺក្នុងគោលបំណង កំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងៗទៀតដែលត្រូវអនុវត្តដើម្បីប្រយុទ្ធ និង ទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជម្ងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជម្ងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តាមន័យខាងលើយើងអាចទាញបាននូវចក្ខុវិស័យតាមបែបសត្យានុម័តមួយចំនួនដូចជា៖ ការការពារសុខភាពសាធារណៈ ជាពិសេសការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ កាត់បន្ថយនូវផលប៉ះពាល់តាមរយៈការឆ្លងនៃជំងឺនេះចំពោះវិស័យសង្គម និងសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ ជំងឺកូវីដ-១៩ ចាប់ផ្តើមផ្ទុះឡើងនៅចុងឆ្នាំ២០១៩ ដោយផ្តើមផ្ទុះចេញពីទីក្រុងវូហាននៃប្រទេសចិន។ ជំងឺនេះបានរាតត្បាតក្នុងពិភពលោក ហើយបានធ្វើឱ្យពិភពលោកទាំងមូលជួបប្រទះទៅនឹងវិបត្តិសកល។ ក្នុងន័យនេះដែរអ្វីដែលគួរឱ្យខ្លាច និងជាបញ្ហាខ្លាំងគឺការឆ្លងរាតត្បាតនៃជម្ងឺនេះធ្វើឲ្យមានមនុស្សស្លាប់ជាច្រើនលាននាក់ឬរាប់ពាន់ និងរាប់ម៉ឺននាក់ក្នុងបណ្តាប្រទេសនីមួយ។ ហេតុនេះហើយទើបប្រទេសនីមួយៗចាប់ផ្តើមដាក់ចេញនូវវិធានការក៏ដូចជាច្បាប់បទដ្ឋានផ្សេងៗដើម្បីធានាដល់ការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺនេះកុំឱ្យមានការឆ្លងរីករាលដាលកាន់តែច្រើនឡើងក្នុងសហគមន៍ តួយ៉ាងដូចជាការដាក់ចេញនូវវិធានការសុខាភិបាល និងវិធានការរដ្ឋបាលផ្សេងៗជាដើម។ តួរយ៉ាងដូចជាប្រទេសកម្ពុជានេះផ្ទាល់បានបង្កើតនូវច្បាប់ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ-១៩ ហើយច្បាប់នេះទៀតសោតបានកំណត់អំពីវិធានការសុខាភិបាល និងវិធានការរដ្ឋបាលដូចជា៖

[16] ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, មូលហេតុនៃការបង្កើតច្បាប់កូវីដ, អាចរកបាននៅ https://www.youtube.com/watch?v=uiRsh97YLtU , (ចូលទស្សនានៅថ្ងៃទី ២២ សីហា ២០២១)។

### ២.៣.១. វិធានការសុខាភិបាល

ចំពោះវិធានការសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺរាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការចំបាច់នានា ដោយអនុលោមតាមច្បាប់ស្តីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលមានជាអាទិ៍ [17]៖

- ការធ្វើអនាម័យ និងការវាស់កំដៅ
- ការពាក់ម៉ាស
- ការរក្សាគម្លាតសុវត្ថិភាពបុគ្គល និងសង្គម
- ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩
- ការធ្វើចត្តាឡីស័ក
- ការដាក់ឲ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
- ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការធ្វើសេចក្តីប្រកាសសុខភាព និង
- ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ។
- ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួងសុខាភិបាល ដើម្បីដាក់ចេញនូវវិធានការសុខាភិបាលផ្សេងៗថែមទៀត សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

[17] មាត្រា៣ នៃច្បាប់ស្តីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

វិធានការសុខាភិបាលធំៗខាងលើនេះមានខ្លឹមសារលម្អិត កំណត់ដោយអនុក្រឹត្យ។ ជាមួយគ្នានេះដែរ អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ-១៩ និងជម្ងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, លេខ៣៧ អនក្រ.បក, ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ មានជាអាទិ៍ ៖

- **ការពាក់ម៉ាស** ៖ រាល់សហគ្រាស់ឬ គ្រឹះស្ថានឯកជន ម្ចាស់អាជីវកម្ម ត្រូវរៀបចំឲ្យមានការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅបុគ្គលម្នាក់ៗ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ក្នុងគោលបំណងដើម្បីទាប់ស្កាត់ការឆ្លងរាលដាលនៃកូវីដ-១៩។ បុគ្គលគ្រប់រូប ត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព នៅតាមទីសាធារណៈ ឬទីកន្លែងដែលមានការជួបជុំមនុស្ស ដើម្បីបង្កាការចម្លងមេរោគកូវីដ-១៩។ ការពាក់ម៉ាស ត្រូវជាកាតព្វកិច្ចដោយផ្អែកតាមសកម្មភាពការងារ ឬស្ថានភាពមុខងាររបស់បុគ្គល និងនៅតាមទីកន្លែងដែលមានហានិភ័យនៃការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។ បុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងទីកន្លែងដែលតម្រូវឲ្យមានការពាក់ម៉ាស ត្រូវកំណត់ដោយក្រសួងសុខភិបាល ដោយផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

- **ការធ្វើអនាម័យ និងការវាស់កំដៅ ៖** រាល់សហគ្រាស ឬគ្រះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវពិនិត្យ និងណែនាំបុគ្គលិក និងបុគ្គលគ្រប់រូប ដែលចូលទៅទីកន្លែងរបស់ខ្លួន ឲ្យធ្វើអនាម័យដើម្បីសម្លាប់មេរោគ វាស់កម្តៅ និងពាក់ម៉ាស់ តាមការកំណត់របស់ក្រសួងសុខាភិបាល ។ រាល់សហគ្រាស ឬ គ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម មិនត្រូវអនុញ្ញាតឲ្យបុគ្គលដែលមិនធ្វើអនាម័យដើម្បីសម្លាប់មេរោគ បុគ្គលដែលមានសិតុណ្ហភាពក្នុងខ្លួនលើសពី ៣៧.៥ (សាមសិបប្រាំពីរក្បៀសប្រាំ)អង្សាសេ ឬបុគ្គលណាដែលមិនពាក់ម៉ាស ចូលក្នុងនិងស្ថិតនៅក្នុងកន្លែងរបស់ខ្លួនឡើយ។

- **ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ៖** ត្រូវមានយ៉ាងតិច ១.៥០ ម៉ែត្រ(មួយម៉ែត្រក្បៀសហាសិបសង់ទីម៉ែត្រ ហើយត្រូវអនុវត្តជាកាតព្វកិច្ចនៅទីកន្លែងធ្វើការ ទីតាំងអាជីវកម្ម ឬទីកន្លែងសាធារណៈនានាដែលមនុស្សច្រើន តាមការកំណត់របស់ក្រសួងសុខភិបាល។ ក្នុងករណីដែលការរក្សាគម្លាតសុវត្ថិភាពបុគ្គល មិនអាចធ្វើទៅបានដោយមូលហេតុ ជាអាទិ៍ សុខភាព កាយសម្បទា សកម្មភាពការងារ ស្ថានភាពមុខរបរ ឬកាលៈទេសៈនៃសកម្មភាព បុគ្គលនោះត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេ

រោគ និងការពាក់ម៉ាស។ រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវរៀបចំនៅទីកន្លែងរបស់ខ្លួន ដើម្បីធានាថាបុគ្គលិក និងអតិថិជន អាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល នៅពេលរង់ចាំ និងពេលកំពុងស្ថិតក្នុងទីកន្លែងរបស់ខ្លួន។ រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម មិនត្រូវទទួលអតិថិជនលើសចំនួនដែលអាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គលនៅក្នុងទីកន្លែងរបស់ខ្លួនឡើង។ អ្នកទទួលខុសត្រូវក្នុងការរៀបចំជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀតជាអាទ៍ កម្មវិធីសាសនា កម្មវិធីប្រពៃណី កម្មវិធីកីឡា ឬកម្មវិធីកំសាន្ត ជាដើម ត្រូវរក្សាគម្លាតសុវត្ថិភាពសង្គម ដោយត្រូវកាត់បន្ថយចំនួនអ្នកចូលរួមឲ្យនៅកម្រិតអប្បបមា និងចៀសវាងការជួបជុំដែលមានលក្ខណៈកុះករកកកុញ ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

- **ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ៖** បុគ្គលគ្រប់រូបដែលស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោមមានកាតព្វកិច្ចត្រូវផ្តល់វត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដល់មន្ត្រីសុខភិបាលមានសមត្ថកិច្ចៈ
  - ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ
  - បុគ្គលដែលមន្ត្រីសុខភិបាលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩
  - បុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកមានផ្ទុកមេរោគកូវីដ-១៩
  - បុគ្គលដែលបានប៉ះពាលដោយប្រយោលជាមួយអ្នកមានផ្ទុកមេរោគកូវីដ-១៩
  - បុគ្គលដែលកំពុងស្ថិតក្នុងការធ្វើចត្តាឡីស័ក និង
  - អ្នកជំងឺកូវីដ-១៩ ដែលកំពុងដាក់ឲ្យនៅដាក់ដោយឡែកដើម្បីទទួលការព្យាបាល។
- **ការធ្វើចត្តាឡីស័ក ៖** ការធ្វើចត្តាឡីស័កត្រូវអនុវត្តចំពោះពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ និងបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬជាមួយអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល។

ការធ្វើចត្តាឡីស័ក ត្រូវធ្វើនៅក្នុងទីកន្លែងធ្វើចត្តាឡីស័កណាមួយ ឬនៅលំនៅឋានរបស់បុគ្គលដែលត្រូវធ្វើចត្តាឡីស័ក តាមការណែនាំរបស់ក្រសួងសុខាភិបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច

ដោយផ្អែកលើស្ថានភាពបុគ្គល ស្ថានភាពគ្រួសារ និងស្ថានភាពលំនៅឋានរបស់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កនោះ។

ការធ្វើចត្តាឡីស័កពាក់ព័ន្ធនឹងជំងឺកូវីដ-១៩មានរយៈពេល ១៤ (ដប់បួន) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល។

ក្នុងកំឡុងពេលធ្វើចត្តាឡីស័ក បុគ្គលដែលធ្វើចត្តាឡីស័ក ត្រូវអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖

១. គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងធ្វើចត្តាឡីស័ក

២. អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល

៣. គោរពតាមគោលការណ៍ណែនាំរបស់មន្ត្រីចត្តាឡីស័ក

៤. មិនត្រូវចាកចេញពទីកន្លែងចត្តាឡីស័ក ដោយគ្មានការអនុញ្ញាតពីមន្ត្រីចត្តាឡីស័ក

៥. សហការជមួយមន្ត្រីសុខាភិបាលដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩

៦. សហការក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីសុខាភិបាល អំពីបុគ្គលដែលសង្ស័យថាអាចមានជំងឺកូវីដ-១៩ឬអ្នកប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងអ្នកជំងឺកូវីដ-១៩ ឬអ្នកដែលត្រូវធ្វើចត្តាឡីស័ក និងផ្តល់ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

- **ការដាក់ឲ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ៖** បុគ្គលដែលមានផ្ទុកមេរោគកូវីដ-១៩ ត្រូវដាក់ឲ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាលនៅទីកន្លែងណាមួយដែលបានត្រូវកំណត់ដោយក្រសួងសុខាភិបាល។

ក្នុងកំឡុងពេលដាក់ឲ្យនៅដាច់ដោយឡែកពីគេដើម្បីទទួលការព្យាបាល អ្នកជំងឺកូវីដ-១៩ ត្រូវអនុវត្តកាតព្វកិច្ចដូចខាងក្រោម ៖

១. គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងព្យាបាល

២. អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល

៣. ត្រូវគោរពការណែនាំរបស់គ្រូពេទ្យក្នុងការព្យាបាល

៤. មិនត្រូវចាកចេញពីទីកន្លែងព្យាបាល ដោយគ្មានការអនុញ្ញាតពីមន្ត្រីសុខាភិបាល

៥. ត្រូវសហការជាមួយមន្ត្រីសុខាភិបាលដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩

៦. សហការក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីសុខភិបាល អំពីបុគ្គលដែលសង្ស័យថាអាចមានជំងឺកូវីដ-១៩ ឬអ្នកប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងអ្នកជំងឺកូវីដ-១៩ ឬអ្នកដែលត្រូវធ្វើចត្តាឡីស័ក និងផ្តល់ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

- **ការចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ-១៩ ៖** ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ត្រូវធ្វើឡើងតាមគោល

ការណ៍ស្ម័គ្រចិត្ត។ ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់ប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងដោយឥតគិតថ្លៃ។

ការចាក់វ៉ាក់សាំងអាចត្រូវធ្វើឡើងជាចាំបាច់ចំពោះបុគ្គលមួយចំនួន ដោយផ្អែកលើស្ថានភាពនៃការងារ ឬស្ថានភាពនៃមុខរបររបស់បុគ្គលនោះ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលអាចដាក់ចេញនូវវិធានការតម្រូវការឲ្យអ្នកដំណើរជាជនបរទេស ដែលធ្វើដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានប័ណ្ណបញ្ជាក់ពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ពេញលេញ។ ការទទួលស្គាល់ប័ណ្ណបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

បុគ្គលដែលបានទទួលចាក់វ៉ាក់សាំងត្រឹមត្រូវតាមការកំណត់របស់ក្រសួងសុខាភិបាល អាចទទួលបានលក្ខខណ្ឌអនុគ្រោះក្នុងការអនុវត្តកាតព្វកិច្ចតាមវិធានសុខាភិបាលនានា ដែលកំណត់ដោយក្រសួងសុខាភិបាល។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលត្រូវចេញសេចក្តីណែនាំអំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- **ការធ្វើសេចក្តីប្រកាសសុខភាព ៖** ពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើដំណើរពីបរទេសចូកមកព្រះរាជាណាចក្រកម្ពុជា និងបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមយយអ្នកជំងឺកូវីដ-១៩ ឬជាអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ត្រូវធ្វើសេចក្តីប្រកាសសុខភាពដោយបំពេញទម្រង់ប្រកាសសុខភាពដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច និងតាមរយៈការផ្តល់ព័ត៌មានចាំបាច់ផ្សេងទៀត តាមការសាកសួររបស់មន្ត្រីសុខាភិបាល ឬមន្ត្រីជំនាញមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

លើកលែងមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល ពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់លិខិតបញ្ជាក់ថាគ្មានមេរោគកូវីដ-១៩មានសុពលភាពរយៈពេល ៧២ម៉ោង មុខធ្វើដំណើរ ចេញដោយអាជ្ញាធរដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសដែលខ្លួនស្ថិតនៅមុខចេញដំណើរ ឬលិខិតបញ្ជាក់ផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខភិបាល។

- **ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩** ៖ ក្នុងករណីដែលមានការសង្ស័យថាសាកសពអាចមានផ្ទុកមេរោគកូវីដ-១៩ គ្រួសារសពត្រូវផ្តល់កិច្ចសហការដល់មន្ត្រីសុខាភិបាលដើម្បីយកសំណាកពីសពយកទៅវិភាគរកមេរោគកូវីដ-១៩។ ក្នុងអំឡុងពេលរង់ចាំលទ្ធផលនៃការវិភាគ សាកសពត្រូវស្ថិតក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ក្រសួងសុខាភិបាលដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីដែលលទ្ធផលនៃការវិភាគយកសំណាកបញ្ជាក់ថាសាកសពគ្មានផ្ទុកមេរោគកូវីដ-១៩នោះទេ ក្រសួងសុខាភិបាលត្រូវប្រគល់សាកសពឲ្យគ្រួសារសពដើម្បីគ្រប់គ្រង និងចាត់ចែងបន្ត។

ករគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ដោយមិនអនុញ្ញាតឲ្យគ្រួសារសពជាអ្នកគ្រប់គ្រង និងចាត់ចែងឡើយ។

ដើម្បីបង្ការកុំឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ សាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ត្រូវយកទៅបូជា ឬបញ្ចុះទៅតាមប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនា ប៉ុន្តែត្រូវអនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល រួមមានជាអាទិ៍៖ ការរៀបចំសាកសពតាមវិធានសុខាភិបាល ការដឹកជញ្ជូនសាកសព និងការកម្រិតចំនួនអ្នកចូលរួមនៅពេលបូជាបញ្ចុះសព។

ការបូជាសាកសពឬការបញ្ចុះសាកសព ត្រូវធ្វើឲ្យបានឆាប់តាមដែលអាចធ្វើទៅបានដោយគ្មានបង្អង់នៅទីកន្លែងណាមួយតាមការកំណត់របស់អាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច។ អាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ត្រូវរៀបចំឲ្យមានការសម្គាល់អត្តសញ្ញាណអដ្ឋិធាតុរបស់សាកសព ឬទីបញ្ចុះរបស់សាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ឲ្យបានច្បាស់លាស់។

ក្រសួងសុខាភិបាល ត្រូវធ្វើការណែនាំលម្អិតអំពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ដើម្បីបង្ការកុំឱ្យមានការចម្លងជំងឺកូវីដ-១៩ដល់អ្នកដទៃ។

នៅក្នុងអនុក្រឹត្យស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតនេះទៀតសោតក៏មានចែងអំពីទោសបញ្ញត្តិទៅលើបុគ្គលដែលល្មើសទៅនឹងវិធានការសុខាភិបាល ហើយទោសបញ្ញត្តិនោះមានចែងដូចខាងក្រោមៈ

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចចំពោះ បុគ្គលដែលមិនអនុវត្តកាតព្វកិច្ចពាក់ម៉ាសដូចមានចែងក្នុងមាត្រា៥ ឬកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គលដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ២០០.០០០ (ពីរសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចចំពោះអ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបចុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលមិនគោរពវិធានការរក្សាគម្លាតសុវត្ថិភាពសង្គម ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់នូវវិធានការរដ្ឋបាលបន្ថែមដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នឹងជំងឺឆ្លងកាចសហាវនឹងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះអ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលបានប្រព្រឹត្តអំពីល្មើសខាងលើ។

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ចំពោះសហគ្រាស ឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលមិនអនុវត្តកាតព្វកិច្ចពាក់ម៉ាស ឬកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គលដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នឹងជំងឺឆ្លងកាចសហាវនឹងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះចំពោះសហគ្រាស ឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលបានប្រព្រឹត្តអំពីល្មើសខាងលើ។

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលមិនសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នេះ មិនធ្វើឲ្យបុគ្គលដែលប្រព្រឹត្តអំពើល្មើសនេះ រួចផុតពីកាតព្វកិច្ចក្នុងាការឲ្យមន្ត្រីសុខាភិបាលយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩នោះទេ។

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលគេចវះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក តែមិនបានបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

អំពើគេចវះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ដែលបានបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ត្រូវផ្តន្ទាទោសតាមកថាខណ្ឌទី២ នៃមាត្រា៧ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នឹងជំងឺឆ្លងកាចសហាវនឹងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ៥០០.០០០ (ប្រាំសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ចំពោះបុគ្គលដែលធ្វើចត្តាឡីស័ក ដែលមិនអនុវត្តនូវកាតព្វិច្ចដូចមានចែងក្នុងចំណុចទី១ និងទី២ នៃមាត្រា១៣ នៃអនុក្រឹត្យនេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍ខាងលើនេះ មិនធ្វើឲ្យបុគ្គលដែលត្រូវធ្វើចត្តាឡីស័ក រួចផុតពីកាតព្វកិច្ចក្នុងការធ្វើចត្តាឡីស័កឡើយ។

ត្រូវពិន័យអន្តរការណ៍ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះអ្នកផ្តើមគំនិត ដឹកនាំ ណែនាំ ញុះញង់ បញ្ចុះបញ្ចូល ឬជួយសម្រួលដោយចេតនា ដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កឲ្យគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬគេចវះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីកន្លែងធ្វើចត្តាឡីស័ក ក្នុងករណីដែលការគេចចេញរបស់មន្ត្រីចត្តាឡីស័ក ឬគេចវះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីកន្លែងធ្វើចត្តាឡីស័ក មិនបណ្តាលឲ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

ត្រូវពិន័យអន្តរការណ៍ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះអ្នកជំងឺកូវីដ-១៩ ដែលត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ដែលមិនអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃកថាខណ្ឌទី២ នៃមាត្រា១៤ នៃអនុក្រឹត្យនេះ។

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ចំពោះបុគ្គលដែលបានចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ល្មើសនឹងមាត្រា១៥ នៃអនុក្រឹត្យនេះ។

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះគ្រឹះស្ថានសុខាភិបាលឯកជនទាំងអស់ ដែលមិនបានធ្វើការជូនដំណឹងបន្ទាន់ទៅក្រសួងសុខាភិបាល ក្នុងការពិនិត្យឃើញថា អ្នកជំងឺដែលកំពុងទទួលសេវាព្យាបាលនៅក្នុងគ្រឹះស្ថានរបស់ខ្លួនតម្រុយបញ្ជាក់ថាជាអ្នកជំងឺដែលគេគេចវេះពីការធ្វើចត្តាឡីស័ក ឬកំពុងគេចចេញពីកន្លែងធ្វើចត្តាឡីស័ក។

ប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់ពីមាត្រា២១ ដល់មាត្រា២៦ នៃអនុក្រឹត្យនេះ ត្រូវកើនឡើងទ្វេដង ក្នុងករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត។

ការសម្រេចអំពីប្រាក់ពិន័យអន្តរការណ៍ក្នុងករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត ត្រូវកើនយ៉ាងតិចទ្វេដងនៃប្រាក់ពិន័យដែលបានសម្រេចលើកមុន និងក្នុងកម្រិតអតិបរមានៃប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ។

ការពិន័យអន្តរការណ៍ដែលមានចែងក្នុងអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

ទម្រង់បែបបទនៃបង្កាន់នៃពិន័យ និងកាគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃអនុក្រឹត្យនេះ បណ្តាលឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរាងកាយ ឬធ្វើឲ្យខូចខាតដដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះបុគ្គលដែលបានប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះអាចត្រូវលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវឬទទួលនូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឲ្យទាន់ពេលវេលា។

ការលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលនូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ចឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងាករទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឲ្យទាន់ពេលវេលា។

ការអនុវត្តបទប្បញ្ញត្តិជំពូកទី៦ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

### ២.៣.២. វិធានការរដ្ឋបាល

ចំពោះវិធានការរដ្ឋបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺរាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការចំបាច់នានា ដោយអនុលោមតាមច្បាប់ស្តីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលមានជាអាទិ៍ [18] ៖

- ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិត ឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឲ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

[18] មាត្រា៤ នៃច្បាប់ស្តីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ធ្វើចរាចរណ៍ចេញ-ចូលតំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បម្រាមគោចរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩
- វិធានការរដ្ឋបាលផ្សេងៗទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

  ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការខាងលើសំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

វិធានការរដ្ឋបាលធំៗខាងលើនេះមានខ្លឹមសារលម្អិត កំណត់ដោយអនុក្រឹត្យ។ ជាមួយគ្នានេះដែរ អនុក្រឹត្យស្តីពីវិធានការងររដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, លេខ៥៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ មានជាអាទិ៍ ៖

- **ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ**

ការធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាចដូចខាងក្រោម ៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម ដែលមិនមានការរឹតត្បិត ឬហាមឃាត់និងដោយមានភ្ជាប់លិខិតបញ្ជាក់ការងារ មុខរបរ ឬអាជីវកម្ម
- ការធ្វើដំណើតទៅស្វែងរកគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ

- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឲ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ តាមកាលកំណត់
- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រឃុំសង្កាត់ដែលខ្លួនរស់នៅដោយចៀសវាងការជួបជុំប្រមូលផ្តុំមនុស្ស
  - ការធ្វើដំណើរដើម្បីអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬសាលាជម្រះក្តី
  - ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើផលប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាសាធារណៈ និង
  - ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ជាអាទិ៍ ករណីមានសមាជិកគ្រួសារកំពុងមានជំងឺធ្ងន់ធ្ងរសង្គ្រោះបន្ទាន់ ឬករណីមានសមាជិកគ្រួសារទទួលមរណភាព។

- **ការរឹតត្បិត ឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឲ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សអាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងក្នុងករណីចាំបាច់ដូច ខាងក្រោម៖

  - ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
  - ការរៀបចំពិធីបុណ្យសព ដោយការគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
  - ការប្រមូលផ្តុំមនុស្សដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
  - ការជួបជុំមនុស្សដើម្បីផ្តល់ជំនួយចាំបាច់នានាដល់ជនងាយរងគ្រោះ ឬជនរងគ្រោះ
  - ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តីនិង

- ការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។

- **ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានផ្អាកបណ្តោះអាសន្ន លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងារនៅក្នុងក្របខណ្ឌមុខងារសាធារណៈ ឬការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារៈតាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអារទ៍ សេវាផ្គត់ផ្គង់អគ្គិសនី, ទឹក, សេវាប្រមូលសំរាម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន
- ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ, ស្ថានីយ៍ប្រេង ឥន្ទនៈ, សេវាប្រសនីយ៍ និងទូរគនាគមន៍
- ភោជនីយដ្ឋាន និងអាហារដ្ឋានដែលលក់អាហារវេចខ្ចប់
- សេវាដឹកជញ្ជូនទំនិញ និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

- **ការរឹតត្បិត ឬការហាមឃាត់ធ្វើចរាចរណ៍ចេញ-ចូលតំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

ការធ្វើចរាចរណ៍ចេញចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងណាមួយ ដែលមានការឆ្លងរាលដាលជំងឺកូវីដ-១៩ អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ។

- **បម្រាមគោចរ**

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងមាត្រា៤នៃអនុក្រឹត្យនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង២០ (ម្ភៃ) ដល់ម៉ោង៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ការដឹកជញ្ជូនទំនិញ ការបំពេញកាតព្វកិច្ចដែលបម្រើប្រយោជន៍សាធារណៈ ការធ្វើដំណើរទៅទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឲ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវអនុញ្ញាតឲ្យនៅបើកដំណើរការស្របតាមមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង២០ (ម្ភៃ) ដល់ម៉ោង៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ និងសេវាសាធារណៈចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

- **ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

រាល់ការធ្វើដំណើរចេញចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងដែលត្រូវបានបិទខ្ទប់ អាចត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងអំឡុងពេលនៃការបិទខ្ទប់ វិធានការរដ្ឋបាលដែលមានចែងក្នុងមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យនេះ ត្រូវបានយកមកអនុវត្តទាំងស្រុង ឬដោយផ្នែក។

ក្នុងអំឡុងពេលនៃការអនុវត្តវិធានបិទខ្ទប់ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានសុខាភិបាលរួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កំដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

- **ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

ទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំណត់ដោយក្រសួងសុខាភិបាល អាចត្រូវបានរឹតត្បិត ឬហាមឃាត់ការធ្វើពាណិជ្ជកម្មតាមគ្រប់រូបភាពនៅលើទីផ្សារ និងការផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា។

- **សិទ្ធិអំណាចក្នុងការដាក់ចេញវិធានរដ្ឋបាល**

**សមត្ថកិច្ចក្នុងការដាក់ចេញវិធានការរដ្ឋបាល** ៖ ការដាក់ចេញវិធានការបិទខ្ទប់រាជធានីឬខេត្ត និងការដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតដែលមានវិសាលភាពអនុវត្តលើសពីដែនដីនៃរាជធានី ឬខេត្តមួយ ឬមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស ត្រូវធ្វើឡើងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈអភិបាលរាជធានី ខេត្ត ត្រូវបានប្រគល់សមត្ថកិច្ចក្នុងការសម្រេចដាក់ចេញវិធានការរដ្ឋបាលណាមួយដែលមានវិសាលភាពអនុវត្តសម្រាប់ផ្នែកខ្លះ ឬទីកន្លែងខ្លះក្នុងដែនដីរាជធានីខេត្ត ឬមានវិសាលភាពអនុវត្តទូទាំងរាជធានី ឬខេត្តរបស់ខ្លួនដែលមានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

**លក្ខខណ្ឌនៃការដាក់ចេញវិធានការរដ្ឋបាល** ៖ ការដាក់ចេញវិធានការរដ្ឋបាលណាមួយស្របតាមអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាបណ្ដោះអាសន្នសម្រាប់ថិរវេលាមិនឲ្យលើសពី ២ (ពីរ) សប្ដាហ៍។ ថិរវេលានេះអាចត្រូវបានសម្រេចបន្ត ឬបញ្ចប់មុនថិរវេលាកំណត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងការសម្រេចដាក់ចេញវិធានការរដ្ឋបាល ស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ។

សិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត ៖ គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវប្រគល់ភារកិច្ចក្នុងការធានាអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី១ នៃមាត្រា១១ នៃអនុក្រឹត្យនេះឲ្យមានប្រសិទ្ធិភាព។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបង្កើតយន្តការចាំបាច់នានា ដើម្បីតាមដាន ត្រួតពិនិត្យ និងអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាម មាត្រា១១ នៃអនុក្រឹត្យនេះ ក្រោមសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ អាចចេញសេចក្ដីណែនាំលម្អិតអំពីការអនុវត្តវិធានការរដ្ឋបាលនានាដែលបានដាក់ចេញស្របតាមអនុក្រឹត្យនេះ ដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្ត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបន្ធូរបន្ថយវិធានការរដ្ឋបាលណាមួយដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី២ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ប៉ុន្តែត្រូវគោរពឲ្យបាននូវរាល់លក្ខខណ្ឌលើកលែងជាក់លាក់នៃវិធានការរដ្ឋបាលនីមួយៗ។ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្នុងករណីបន្ទាន់និងចាំបាច់ គណៈអភិបាលរាជធានី ខេត្តមានសិទ្ធិដាក់វិធានការរដ្ឋបាលផ្សេងទៀត សំដៅធានាដល់ប្រសិទ្ធិភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងប់ស្កាត់ជំងឺនេះមិនឲ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

នៅក្នុងអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតនេះទៀតសោតក៏មានចែងអំពីទោសបញ្ញត្តិទៅលើបុគ្គលដែលល្មើស និងមិនគោរពទៅនឹងវិធានការរដ្ឋបាល ហើយទោសបញ្ញត្តិនោះមានចែងដូចខាងក្រោម៖

- ត្រូវផ្តន្ទាទោសស្របតាមមាត្រា១០ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនគោរពដោយចេតនានូវវិធានការរដ្ឋបាលដែលមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បែបបទនីតិវិធីលម្អិតសម្រាប់ការដាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយគណៈអភិបាលរាជធានី ខេត្ត។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ត្រូវផ្តន្ទាទោសស្របតាមមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលប្រព្រឹត្តអំពើរារាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការរដ្ឋបាលដែលមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។
- ត្រូវផ្តន្ទាទោសស្របតាមមាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៩ នៃអនុក្រឹត្យនេះ។
- មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាច តាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃអនុក្រឹត្យនេះ បណ្តាលឲ្យប៉ះពាល់សិទ្ធិសេរីភាព បូរភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតទ្រព្យ

សម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

- ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ អាចត្រូវលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវ ឬការទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ពីព័ត៌មានដល់មន្ត្រីសុខាភិបាល មន្ត្រីមានសមត្ថកិច្ចឬបានផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឲ្យទាន់ពេលវេលា។

ការលើកលែងឲ្យរួចផុតពីការទទួលខុសត្រូវ ឬការទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ បានបង្ហាញប្រាប់ពីព័ត៌មានដល់មន្ត្រីសុខាភិបាល មន្ត្រីមានសមត្ថកិច្ចឬបានផ្តល់កិច្ចសហការចាំបាច់នានា ដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឲ្យទាន់ពេលវេលា។

- ការអនុវត្តបទប្បញ្ញត្តិជំពូកទី៤ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តិក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

# ជំពូកទី ៣
# ផលប៉ះពាល់ទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋនៃច្បាប់ប្រឆាំងកូវីដ-១៩

ថ្វីត្បិតតែច្បាប់កូវីដ-១៩ ឬច្បាប់ពិសេសមួយនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារសុខភាពសាធារណៈ ក៏ដូចជាអាយុជីវិតរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយនូវការឆ្លងជំងឺកូវីដ-១៩ នេះ ចំពោះវិស័យសង្គម និង វិស័យសេដ្ឋកិច្ចក៏ពិតមែន ក៏ប៉ុន្តែការរឹតត្បិតទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក៏មាននៅក្នុងច្បាប់មួយនេះដែរ។ ជាក់ស្តែងនោះគឺ ការកំណត់អំពីវិធានការរដ្ឋបាល ដែលបានហាមឃាត់នូវសិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ប្រជាពលរដ្ឋនូវក្នុងកំឡុងពេលចាប់ផ្តើមអនុវត្តច្បាប់។

## ៣.១. ទស្សនៈក្រុមអ្នកជំនាញសិទ្ធមនុស្ស អ.ស.ប

មតិរបស់អង្គការសង្គមស៊ីវិល ជាពិសេសពីសំណាក់ក្រុមអ្នកជំនាញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានសំដែងកង្វល់ជាខ្លាំងជុំវិញច្បាប់កូវីដ-១៩នេះ។

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នេះត្រូវបានគេមើលឃើញថារំលោភសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដូចជា សិទ្ធិក្នុងការដើរហើរ សិទ្ធិជួបប្រជុំគ្នាដោយសន្តិវិធី សិទ្ធិមានការងារធ្វើ និងសិទ្ធិក្នុងការប្រកបអាជីវកម្ម ហើយលើសពីនេះទៅទៀតនោះ ដោយបន្ថែមពីលើវិធានការរដ្ឋបាល គឺច្បាប់មួយនេះក៏បានអនុញ្ញាតឱ្យមាននូវវិធានការព្រហ្មទណ្ឌទៅលើបុគ្គលណាដែលមិនគោរពអនុវត្ត និងមានចេតនាធ្វើឱ្យមានការឆ្លងនៃជំងឺកូវីដ-១៩ [19] ។

នៅក្នុងអត្ថបទនៃសេចក្តីប្រកាសព័ត៌មានមួយរបស់ក្រុមអ្នកជំនាញសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានលើកឡើងដូច្នេះថា "ការរឹតត្បិតលើសេរីភាព និងសិទ្ធិជាមូលដ្ឋាន ដោយផ្អែកលើសុខភាពសាធារណៈមិនត្រូវរំលោភលើសិទ្ធិសេរីភាពដែលបានធានាការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ"។ " យើងមានមានកង្វល់ថាវិធានការរដ្ឋបាល និងវិធានការព្រហ្មទណ្ឌរួមទាំងការដាក់ទោសពន្ធនាគាររយៈពេលវែងហួសហេតុ និងការពិន័យជាប្រាក់ដែលមានចែងក្នុងច្បាប់នេះ ទំនងជាមិនមានសមាមាត្រ និងមិនចាំបាច់ឡើយ

[19] OHCHR ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ក្រុមអ្នកជំនាញ អ.ស.ប ជម្រុញឱ្យកម្ពុជាពិនិត្យឡើងវិញនូវអភិក្រមរបស់ខ្លួនចំពោះជំងឺកូវីដ-១៩, អាចរកបាននៅ https://www.ohchr.org/Documents/Press/Khmer-version-26985.pdf (ចូលទស្សនានៅថ្ងៃទី២២ សីហា ២០២១)។

រាល់វិធានការដែលបានចាត់ចែងឡើងសំដៅប្រយុទ្ធប្រឆាំង និងការឆ្លងរាលដាល រួមទាំងទោសទណ្ឌដែលអាចមានគួរតែធ្វើក្នុងករណីចាំបាច់ និងមានលក្ខណៈសមាមាត្រ ហើយមិនត្រូវបានប្រើប្រាស់ហួសហេតុឡើយ ”។ បន្ថែមពីលើបញ្ហាច្បាប់នេះវិញក្រុមអ្នកជំនាញក៏បានបង្ហាញនូវកង្វល់មួយចំនួនទៀតទាក់ទងនឹងបម្រាមគោចរចំនួនពីរសប្តាហ៍នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដែលរដ្ឋបាលរាជធានីភ្នំពេញចាប់ផ្តើមអនុវត្តបម្រាមគោចរហាមឃាត់ការធ្វើដំណើរនៅពេលរាត្រីនៅចន្លោះចាប់ពីម៉ោង៨ ដល់ម៉ោង ៥ទៀបភ្លឺ សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ។ នៅក្នុងសេចក្តីសម្រេចវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នេះទៀតសោតក៏បានបញ្ជាក់ពីការផ្អាកជាបណ្តោះអាសន្នចំពោះតូបអាហារ អាហារដ្ឋាន ភោជនីយដ្ឋាន ហាងភេសជ្ជៈ ដែលទទួលអតិថិជនចូលមកទទួលទាន អាហារ ភេសជ្ជៈ គ្រឿងស្រវឹងនៅចន្លោះពីម៉ោង៨ ដល់ម៉ោង ៥ទៀបភ្លឺជាកំហិត ប៉ុន្តែអាចលក់ជាលក្ខណៈវិចខ្ចប់។ សេចក្តីសម្រេចនូវការដាក់ចេញវិធានការរដ្ឋបាលជាបណ្តោះអាសន្ននេះត្រូវបានចេញនៅថ្ងៃទី០១ មេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ។

ជុំវិញបញ្ហានេះដែរក្រុមអ្នកជំនាញក៏បានលើកឡើងផងដែរថា “ ដោយពិចារណាទៅលើការកើនឡើងនៃបំណុលនៅកម្ពុជា វិធានការទាំងនេះរឹតតែធ្វើឱ្យប៉ះពាល់ថែមទៀតដល់ប្រជាជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះបំផុត ដែលពួកគេបានទទួលរងស្រាប់ហើយនូវការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩នេះ ហើយវាជាហានិភ័យក្នុងការរុញច្រានពួកគេឲ្យធ្លាក់ក្នុងភាពក្រីក្រ ”។

## ៣.២. ទស្សនៈរបស់មន្ត្រីរាជរដ្ឋាភិបាល

នៅក្នុងការការពារសេចក្តីព្រាងច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅឯព្រឹទ្ធសភា គឺលោកបានលើកឡើងជាអាថ៌ថា “ ច្បាប់នេះធ្វើឡើងមិនមែនជាការរំលោភសិទ្ធិសេរីភាពរបស់បុគ្គលទេ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺជាការការពារសិទ្ធិរបស់បុគ្គលផ្សេងទៀត ”[20]។ ជាមួយគ្នានេះដែរលោក ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏បានលើកឡើងទាក់ទងចំពោះទោសទណ្ឌនៅក្នុងច្បាប់នេះផងដែរថា “ ជំងឺកូវីដ-១៩ មិនមែនជាជំងឺធម្មតាទេ តែជាជំងឺដែលអាចសម្លាប់ផ្តាច់អាយុជីវិតមនុស្សបាន។ ជាក់ស្តែងនូវមាត្រា៩ គឺការចម្លងដោយចេតនាទៅអ្នកដទៃ តើមានខុសគ្នាអ្វីទៅនឹងចេតនាសម្លាប់អ្នកដទៃ? ហើយនេះមិន

[20] ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, មូលហេតុនៃការបង្កើតច្បាប់កូវីដ, អាចរកបាននៅ https://www.youtube.com/watch?v=uiRsh97YLtU , (ចូលទស្សនានៅថ្ងៃទី ២២ សីហា ២០២១)។

មែនមួយនាក់ទេ គឺអាចឆ្លងពីមួយទៅមួយ ឬរាលដាលទៅមួយទៀត ហើយអាចស្លាប់ច្រើនអ្នកទៅទៀត និងបង្កឲ្យមានភាពវឹកវរក្នុង សង្គម។ ដូច្នេះយើងមិនអាចមើលស្រាល មិនអាចចាត់ទុកជម្ងឺនេះថាជាជំងឺគ្រុនធម្មតាដែលអាចផឹកថ្នាំមួយគ្រាប់ ពីរគ្រាប់ជានោះទេ ហើយមកដល់ម៉ោងនេះមិនទាន់មានថ្នាំណាមួយដ៏ស័ក្កសិទ្ធិដែលថាដាក់ទៅព្យាបាលជំងឺនេះបានទេ ហើយប្រសិនបើរកឃើញថ្នាំបែបនេះ ច្បាប់នេះយើងអាចលុបចេញវិញបាន។ ហើយកម្ពុជាការធ្វើច្បាប់ទាក់ទងទៅនឹងជម្ងឺនេះមិនមែនជាលើកទីមួយទេ កម្ពុជាបានធ្វើច្បាប់ស្តីពីការប្រឆាំងទៅនឹងការរាលដាលនៃជំងឺអេដស៍ឆ្នាំ២០០២ រួចមកហើយ។ អ្នកដែលដឹងថាខ្លួនឯងមានជំងឺអេដស៍ ទៅចម្លងជំងឺនេះដល់អ្នកដ៏ទៃស្មើរនឹងបទមនុស្សឃាតដោយចេតនាដោយសារជំងឺអេដស៍អត់មានថ្នាំព្យាបាល ហើយច្បាប់នេះកំពុងនូវជាធរមាននៅកម្ពុជានូវឡើយទេ។ ចុះបើប្រៀបជំងឺអេដស៍ទៅនឹងជំងឺកូវីដ តើមួយណាធ្ងន់ធ្ងរជាង? ឥលូវទាក់ទងនឹងជំងឺកូវីដដែលនៅក្នុងបទបញ្ញតិនេះ មាត្រា៩ ចម្លងជំងឺកូវីដដោយចេតនាមានទោសពី៥ឆ្នាំ ទៅ១០ឆ្នាំ ប៉ុន្តែចម្លងជំងឺអេដស៍ដោយចេតនាទៅអ្នកដទៃមានទោសពី១០ឆ្នាំ ទៅ១៥ឆ្នាំ ហើយនេះមិនមែនជារឿងថ្មីទេ។ អញ្ចឹងរហូតដល់ថាធ្វើច្បាប់មួយដើម្បីការពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈ បែរជាមានមតិរិះគន់ថាច្បាប់នេះដាក់ទោសធ្ងន់ធ្ងរទៅវិញ។ ដូច្នេះសុំបញ្ជាក់ជូនថា ច្បាប់នេះមិនមែនធ្វើសម្រាប់ដាក់ទោសប្រជាជននោះទេ គឺច្បាប់នេះធ្វើដើម្បីការពារអាយុជីវិតប្រជាជន និងសុខភាពសាធារណៈ ហើយដាក់ទោសចំពោះតែជនទុច្ចរិត ឬខិលខូចមួយចំនួនតូច ដែលជាអ្នកបង្កឲ្យមានភាពវឹកវរក្នុងសង្គម ហើយដែលអាចឈានទៅដល់ការបាត់បង់អាយុជីវិតរបស់ប្រជាជន ” ។

តាមការផ្តល់បទសម្ភាសនៅក្នុងកម្មវិធីសំឡេងការពិតអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ជុំវិញប្រធានបទ“ តើវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ក្នុងការប្រយុទ្ធប្រឆាំងកូវីដ-១៩ ជាការរំលោភបំពានសិទ្ធិមនុស្សដែរឬទេ?” ឯកឧត្តម ជិន ម៉ាលីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងយុត្តិធម៌បានលើឡើងដូច្នេះថា “ វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការច្បាប់ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ-១៩នេះ មិនមែនជាការរំលោភសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនោះទេ។ ព្រោះបានផ្អែកទៅលើមូលដ្ឋានចំនួនបី : ទី១ (មួយ) ការអនុវត្តជាអន្តរជាតិ , ទី២ (ពីរ) បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ , ទី៣ (បី) បទដ្ឋានសិទ្ធិមនុស្សជាតិរបស់កម្ពុជា ”[21] ។

[21] ជិន ម៉ាលីន អនុប្រធាន និងអ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា, "តើវិធានការរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ១៩ ជាការរំលោភបំពានសិទ្ធិមនុស្សឬទេ?" អាចរកបាននៅ https://www.youtube.com/watch?v=Vl2HhqcLX_k (ចូលទស្សនានៅថ្ងៃទី២២ សីហា ២០២១)។

ផ្អែកទៅលើការអនុវត្តជាអន្តរជាតិយើងសង្កេតឃើញថា ពិភពលោកនៅពេលដែលប្រឈមទៅនឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩នេះ គឺមានបណ្តាប្រទេសជាច្រើនបានដាក់ចេញនូវវិធានការយ៉ាងតឹងរឹងក្នុងការទប់ស្កាត់ប្រយុទ្ធប្រឆាំងទៅនឹងកូវីដ-១៩ និងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋរបស់ប្រទេសគេផងដែរ ក្នុងនោះមានដូចជាការបិទប្រទេសទាំងមូល បិទទីក្រុង ឬតំបន់មួយចំនួន មានបម្រាមគោចរ និងហាមឃាត់ការធ្វើដំណើរ ការជួបជុំជាដើម។ល។ បន្ថែមពីនេះទៅទៀតក៏មាន ការដាក់ទោសទណ្ឌ ទណ្ឌកម្ម និងពិន័យទៅលើអ្នកដែលបំពានវិធានទាំងនោះផងដែរ ដូច្នេះកម្ពុជាមិនមែនជាករណីដោយឡែកនោះទេក្នុងការដាក់ចេញនូវវិធានការទាំងអស់នេះ ហើយបើប្រៀបធៀបរវាងវិធានការរបស់កម្ពុជា ទៅនឹងបណ្តាប្រទេសផ្សេងនៅក្នុងពិភពលោកគឺវិធានការរបស់ប្រទេសកម្ពុជាយើងនូវមានភាពស្រាលជាងគេឆ្ងាយណាស់។

ចំណែកឯចំណុចទីពីរពាក់ព័ន្ធទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេសនោះគឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនៅក្នុងកតិកាសញ្ញានេះទៀតសោតយើងឃើញថាមានការបែងចែកសិទ្ធិសេរីភាពជាពីរ៖ ទី១ (មួយ) សិទ្ធិដាច់ខាត និងទី២ (ពីរ) សិទ្ធិមិនដាច់ខាត។ ដោយឡែកសិទ្ធិដាច់ខាត គឺជាសិទ្ធិដែលរដ្ឋាភិបាលមិនមានសិទ្ធិកំហិត ឬក៏ដកហូតនោះទេទោះបីក្នុងកាលៈទេសៈណាក៏ដោយ។ ឧទាហរណ៍ដូចជា៖ សិទ្ធិរស់រានមានជីវិត សិទ្ធិរួចផុតពីការទទួលទារុណកម្មជាដើម។ល។ ចំណែកសិទ្ធិមិនដាច់ខាត នោះមានដូចជា សិទ្ធិសេរីភាពក្នុងការដើរហើរ សិទ្ធិសេរីភាពក្នុងការជួបប្រជុំ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ឬសិទ្ធិឯកជន នេះដោយយោងទៅតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានអនុញ្ញាតឱ្យមានការកំហិតឬកម្រិត និងដកហូតនៅក្នុងកាលៈទេសៈណាមួយបានដើម្បីប្រយោជន៍សាធារណៈរួមមាន សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងការពារទៅដល់សុខភាពសាធារណៈជាដើម ហើយការកំហិត ឬការរឹតត្បិតនេះត្រូវធ្វើឡើងដោយច្បាប់។

ចំពោះមូលដ្ឋានទីបីពាក់ព័ន្ធទៅនឹងបទដ្ឋានសិទ្ធិមនុស្សជាតិ ជាពិសេសគឺរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក៏មាននូវការធានាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់បែបយ៉ាងទាំងអស់ ប៉ុន្តែនៅក្នុងក្នុងរដ្ឋធម្មនុញ្ញក៏បានបញ្ញត្តិផងដែរថា ការអនុវត្តសិទ្ធិនោះគឺត្រូវកំណត់ដោយច្បាប់ ដូច្នេះយើងត្រូវដឹងថាសិទ្ធិទាំងអស់មិនមែនត្រូវបានអនុវត្តដោយអានាធិបតេយ្យ ឬគ្មានព្រំដែនកំណត់នោះទេ គឺត្រូវមានច្បាប់កំណត់ព្រំដែននៃសិទ្ធិ ហើយការកំណត់នេះគឺដើម្បីប្រយោជន៍សាធារណៈរួមមាន សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬ សុខភាពសាធារណៈជាដើម។ល។ ម្ល៉ោះហើយការរៀបចំច្បាប់ប្រឆាំងកូវីដ-១៩ រួមមានបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធផ្សេងទៀតសំដៅដល់ការការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សណ្តាប់ធ្នាប់សាធារណៈ និងសុខភាពសាធារណៈនេះគឺផ្អែកទៅលើស្មារតីនៃរដ្ឋធម្មនុញ្ញទាំងស្រុងតែម្តង។

សរុបមកការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលដែលរួមមាន វិធានការសុខាភិបាល វិធានការរដ្ឋបាល វិធានការច្បាប់ដែលមានចរិតកំហិតនូវសិទ្ធិសេរីភាពមួយចំនួនរបស់ប្រជាពលរដ្ឋដែលមិនមែនជាសិទ្ធិដាច់ខាតនោះរួមមាននូវ សិទ្ធិសេរីភាពក្នុងការដើរហើរ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិសេរីភាពក្នុងការជួបប្រជុំមួយចំនួននេះ មិនមែនជា

ការរំលោភបំពានទៅលើសិទ្ធិមនុស្សនោះទេ ព្រោះថាការធ្វើនេះគឺក្នុងគោលបំណងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ រក្សាសន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសុខភាពសាធារណៈ ហើយត្រូវបានអនុញ្ញាតដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ បទដ្ឋានសិទ្ធិមនុស្សជាតិកម្ពុជា រួមទាំងការអនុវត្តទូទៅរបស់បណ្តាប្រទេសប្រជាធិបតេយ្យនៅលើពិភពលោកនេះផងដែរ។

## ៣.៣. ទស្សនៈចម្រុះ

Newsroom Cambodia បានសម្ភាសន៍ប្រជាពលរដ្ឋតាមរយៈបណ្តាញសង្គម និងដកស្រង់មតិយោបល់ ការយល់ឃើញចម្រុះ ព្រមទាំងការបកស្រាយពន្យល់ ពីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អ្នកឃ្លាំមើលសង្គម និងប្រជាពលរដ្ឋមួយចំនួន ជុំវិញការដាក់កម្រិតផាកពិន័យ និងដាក់ទោសទណ្ឌ របស់ច្បាប់កូវីដ-១៩ នេះ [22]។

លោក សំបាន ច័ន្ទដារ៉ា វ័យ១៨ឆ្នាំ ជានិស្សិតឆ្នាំទី១ កំពុងសិក្សានៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ បានលើកឡើងថា ខ្លួនបានអានលម្អិតច្បាប់ថ្មីស្តីអំពីកូវីដ-១៩នេះ តាំងពីអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សរបស់ទីស្តីការគណៈរដ្ឋមន្ត្រីបានផ្សាយ ដែលមានលម្អិតច្រើនជំពូក និងមាត្រា។ យុវជនរូបនេះយល់ឃើញថា ច្បាប់នេះមានទាំងចំណុចល្អ និងចំណុចមិនល្អ ដោយសម្អាងថា ចំណេះដឹងប្រជាជននៅមានកម្រិត ជាពិសេសពួកគាត់ មិនសូវបានយល់ដឹងស៊ីជម្រៅអំពីកត្តាជីវសាស្ត្ររបស់ជំងឺកូវីដ-១៩ ជំណែកការផ្សព្វផ្សាយច្បាប់នេះឲ្យពលរដ្ឋបានដឹងមិនទាន់ទូលំទូលាយនៅឡើយ។

យុវជន ច័ន្ទដារ៉ា៖ «ចំណុចល្អសម្រាប់ច្បាប់នេះនៅត្រង់ថា ជាគោលដៅសុទិដ្ឋិនិយម សម្រាប់ប្រទេសជាតិយើង ដែលកំពុងរងគ្រោះដោយសារការរីករាលជំងឺកូវីដ-១៩ ក្នុងសហគមន៍ អ៊ីចឹងរដ្ឋាភិបាលបើគួរពុំគួរ ក៏ត្រូវបង្កើតច្បាប់មួយដើម្បីទប់ស្កាត់ការរាលដាល។ ក្នុងដំណាក់កាលមួយដែលប្រជាពលរដ្ឋ គាត់មិនសូវយកចិត្តទុកដាក់ និងមិនសូវជាខ្វល់ខ្វាយ រដ្ឋាភិបាលបង្កើតច្បាប់ហ្នឹងមកដើម្បីបង្អាក់ និងដាស់តឿនស្មារតីប្រជា

[22] Newsroom Cambodia, ទស្សនៈចម្រុះរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល អ្នកវិភាគ និងរដ្ឋាភិបាល ជុំវិញច្បាប់ទប់ស្កាត់ជំងឺកូវីដ-១៩ , អាចរកបាននៅ https://newsroomcambodia.com/group-vi/2021/03/22/the-multi-opinions-on-new-law-of-covid19/ (ចូលទស្សនានៅថ្ងៃទី២២ សីហា ២០២១)។

ពលរដ្ឋ ដោយការដាក់កំហិតបង្ខំ ព្រោះពេលខ្លះសម្រាប់ប្រទេសយើងទាល់តែបង្ខំ បានទទួលផល»។ លោកបន្ថែមថា៖ «ក្នុងលក្ខណៈទុទ្ទិដ្ឋិនិយមវិញ គឺការផាកពិន័យជាប្រាក់រហូតដល់ ២លានរៀល ឬលើសពីនេះ ប្រជាពលរដ្ឋខ្លះ គាត់គ្មានប្រាក់ច្រើនដល់នេះទេ និងជាប់ពន្ធនាគារដល់៥ឆ្នាំ ១០ឆ្នាំ ២០ឆ្នាំ វាហាក់ធ្ងន់ធ្ងរពេក»។

កញ្ញា ទីន សុលីដា ក្នុងវ័យ២៤ឆ្នាំ បច្ចុប្បន្នជាបុគ្គលិកបម្រើការ ក្នុងក្រុមហ៊ុនមួយនៅរាជធានីភ្នំពេញ។ យុវតីមានដើមកំណើតពីខេត្តតាកែវរូបនេះបាននិយាយថា ការដាក់ចេញច្បាប់ថ្មីទប់ស្កាត់ជំងឺរាតត្បាតកូវីដ១៩នេះ វាមិនជាធ្ងន់ធ្ងរពេកទេ សម្រាប់ប្រជាជនទូទាំងប្រទេស។

កញ្ញាបញ្ជាក់ថា៖ «ដោយការណ៍នេះនាំឱ្យការរាតត្បាតនៃជំងឺអាចនឹងធូរស្រាលខ្លះ ប្រសិនបើប្រជាជនទាំងអស់ចូលរួមសហការ ព្រោះវាមានភាពងាយស្រួលក្នុងការតាមដាន ស្វែងរកប្រភពនៃជំងឺ និងអាចទប់ស្កាត់ចំពោះប្រជាជន ដែលមិនទាន់ប៉ះពាល់អ្នកមានផ្ទុកជំងឺ ដោយអាចបង្ការមិនឱ្យឆ្លងចូលក្នុងសហគម៍ ក៏ដូចជាគ្រួសាររបស់ពួកគាត់ដែរ។ សម្រាប់ច្បាប់ មិនបង្ខំមនុស្សឱ្យស្លាប់ទេ មានតែជំងឺទេដែលឱ្យមនុស្សស្លាប់»។

ទន្ទឹមនឹងគុណសម្បត្តិ សុលីដា ក៏បានលើកឡើងពីផលវិបាកផងដែរ ដោយសង្កត់ថា ការផាកពិន័យ និងដាក់ទោសទណ្ឌ គឺប៉ះពាល់ខ្លាំង ចំពោះអាជីវករតាមផ្សារបន្លែ និងតាមតូបលក់ទំនិញតូចៗ ជាពិសេសប្រជាជនដែលមានជីវភាពមធ្យម អាចធ្លាក់ទៅទាប និងទាប កាន់តែធ្លាក់ទាបន្ថែមទៀត។

កញ្ញាបញ្ជាក់ថា៖ «ម្នាក់ៗនឹងមិនហ៊ានចេញក្រៅផ្ទះ ដោយខ្លាចឆ្លងជំងឺទៅត្រូវផាកពិន័យ ជាប់ទោសដាក់ពន្ធនាគារ ប៉ុន្តែការគ្មានលទ្ធភាពសងបំណុលគេ ខ្លាចក្រុមគ្រួសារដាច់ពោះ ខ្លាចគ្រប់សព្វបែបយ៉ាង សរុបទៅការផាកពិន័យ និងដាក់ទោស ដូចដាក់បន្ទុកបន្ថែម»។

សុលីដាបន្ថែមថា រឹតតែអាក្រក់ទៅទៀត ចំពោះជនអនាថាគ្មានទីពឹង និងអ្នកមានលទ្ធភាព ពួកគាត់មានលទ្ធភាពឯណា នឹងមានប្រាក់ទៅបង់ថ្លៃផាកពិន័យ។

លោក កេត ប៊ុនធឿន មានវ័យ ៣៨ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានបង្ហាញការយល់ឃើញថា ច្បាប់នេះល្អប្រសើរ និងចាំបាច់បន្ទាន់ ក្នុងការបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ ប៉ុន្តែច្បាប់នេះអាចថាចេញរាងយឺតបន្តិច និងថា ការផ្សព្វផ្សាយមិនសូវទូលំទូលាយ ឲ្យមានប្រសិទ្ធភាពខ្ពស់។

លោក កេត ប៊ុនធឿន បញ្ជាក់ថា៖ «ស្ថានភាពកូវីដបច្ចុប្បន្នរាលដាលខ្លាំង ដូចនេះរដ្ឋមិនគួរ ត្រឹមកំណត់កន្លែងចាំបាច់សម្រាប់ការពាក់ម៉ាស់ទេ គួរ ត្រូវតែ កំណត់ថាគ្រប់ទីកន្លែងសាធារណៈ ឬឯកជន គ្រប់មនុស្សត្រូវតែពាក់ម៉ាស់ជាកំហិត ដោយរដ្ឋត្រូវចាត់ខាងមូលដ្ឋានឲ្យអនុវត្តច្បាប់នេះ ហើយរដ្ឋខ្លួនឯងក៏ត្រូវធ្វើឱ្យតម្លៃ និងចំនួនម៉ាស់ គឺសមរម្យនឹងពលរដ្ឋទិញពាក់។

លោក ប៊ុន ធឿន បន្ថែមថា ការបកស្រាយច្បាប់នេះក៏មិនទាន់លម្អិតគ្រប់គ្រាន់នៅឡើយ។ លោកថា៖ «ឯ ការបកស្រាយច្បាប់ មិនទាន់បានច្បាស់លាស់ ដូចជាការកំណត់តំបន់ ដែលតម្រូវឱ្យពាក់ម៉ាស់ ធ្វើឡើងមិនបានទូលំទូលាយ ប្រជាជនភាគច្រើនលើសលុប នៅតែយល់ច្រឡំថាត្រូវពាក់ម៉ាស់គ្រប់ទីកន្លែង។ ក្នុងខ្លឹមសារច្បាប់សោត ដូចជាមិនមានចែងអំពីកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ដែលនៅស្និទ្ធនឹងពលរដ្ឋទេ បើដូចនេះកាតព្វកិច្ច និងតួនាទីរបស់អ្នកទទួលខុសត្រូវមិនច្បាស់លាស់ ធ្វើឲ្យច្បាប់បានត្រឹមតែច្បាប់ តែការអនុវត្ត គឺនៅតែរញ៉េរញ៉ៃ គ្មានសណ្ដាប់ធ្នាប់ដដែល»។

លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានផ្ដល់សម្ភាសដល់ Newsroom Cambodia កាលពីថ្ងៃទី១២ មីនា នេះ ជុំវិញការយល់ឃើញរបស់លោកស្រីថា ការតាក់តែងច្បាប់ធ្វើឡើងដោយតក់ក្រហល់ ឬមិនទាន់មានការចែករំលែកព័ត៌មាន ឱ្យសាធារណជនបានដឹងឮទូលំទូលាយនៅឡើយ។

លោកស្រី ចក់ សុភាព៖ «ទោសប្បញ្ញត្តិ មានការដាក់ទោសទណ្ឌពី ១០ ទៅ ២០ឆ្នាំនេះ ខ្ញុំយល់ថាវាហាក់បីដូចជាធ្ងន់ធ្ងរ ហើយត្រូវធ្វើយ៉ាងម៉េច ចែងឱ្យច្បាស់ពាក់ព័ន្ធនឹង ការចម្លងជំងឺកូវីដ១៩ ដោយចេតនាហ្នឹង ថាតើលក្ខខណ្ឌបែបណា ដែលយើងកំណត់ថាអាចជាការចម្លងជំងឺដោយចេតនា កន្លែងនេះជាចំណុចមួយ ដែលវានឹងអាចប្រឈមសម្រាប់ពលរដ្ឋ។ ជួនកាលជាការបកស្រាយច្បាប់តាមឆន្ទៈរបស់សមត្ថកិច្ច អ៊ីចឹងពលរដ្ឋអាចនឹងរងគ្រោះទ្វេដង រងគ្រោះមួយដោយសារជំងឺ ហើយរងគ្រោះមួយទៀតដោយសារការដាក់ទោសទណ្ឌ»។

លោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានថ្លែងក្នុងសន្និសីទសារព័ត៌មានរួមគ្នាជាមួយក្រសួងសុខាភិបាល ដើម្បីស្រាយបំភ្លឺ និងពន្យល់ជាសាធារណៈជុំវិញការបង្កើតច្បាប់ថ្មីនេះ កាលពីទី១៥ ខែមីនា ឆ្នាំ២០២១ កន្លងទៅថា ច្បាប់កូវីដនេះ បង្កើតឡើងក្នុងស្ថានភាពបន្ទាន់ និងប្រកាសជាការប្រញាប់ ដោយត្រូវចូលជា

ធរមានភ្លាមក្រោយប្រកាស ព្រមទាំងប្រដេញឱ្យទាន់សភាពការណ៍នៃការឆ្លងរបស់ជំងឺកូវីដ១៩ ក្នុងសហគមន៍ ២០កុម្ភៈ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមរយៈការរៀបរាប់ និងការបកស្រាយពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌច្បាប់កូវីដ-១៩នេះ គឺមានមែននូវការរឹតត្បិតសិទ្ធិសេរីភាពមួយចំនួនដូចជាការជួបជុំ ការដើរហើរអ្វីផ្សេងៗ។ល។ ថ្វីត្បិតតែក្នុងដំណើរការនៃការអនុវត្តច្បាប់នេះមានការរឹតត្បិតបន្តិចមែន ប៉ុន្តែក៏មាននូវការបន្ធូរបន្ថយ ឬការលើកលែងមួយចំនួនសម្រាប់ប្រជាពលរដ្ឋផងដែរ។ ច្បាប់កូវីដ-១៩នេះអនុម័តឡើងមិនមែនជាការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋនោះទេ ដោយសារច្បាប់នេះបង្កើតឡើងដោយមានការផ្អែកទៅលើមូលដ្ឋានចំនួនបី។ ទីមួយ គឺយោងទៅលើការអនុវត្តជាអន្តរជាតិ ដែលជំងឺកូវី-១៩ត្រូវបានពិភពលោកចាត់ទុកថាជាវិបត្តិសកលព្រោះវាបានជះឥទ្ធិពល និងធ្វើឲ្យមានផលប៉ះពាល់ខ្លាំងទៅលើវិស័យសង្គម សេដ្ឋកិច្ច ហើយជាពិសេសនោះគឺសុខភាពសាធារណៈ និងអាយុជីវិតរបស់ប្រជាជន ដូច្នេះបណ្តាប្រទេសជាច្រើនត្រូវដាក់ចេញនូវវិធានការដ៏តឹងរឹង ឬច្បាប់បទដ្ឋានណាមួយដើម្បីគាំពារចំពោះវិស័យសង្គម វិស័យសេដ្ឋកិច្ច និងអាយុជីវិតប្រជាជន។ ចំពោះការផ្អែកទៅលើមូលដ្ឋានទីពីរនោះគឺច្បាប់ពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សអន្តរជាតិដែលមានកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលអនុញ្ញាតឲ្យមាននូវការកម្រិតនូវសិទ្ធិមួយចំនួនដូចជាការជួបជុំ ការដើរហើរ និងការបញ្ចេញមតិ ដែលកំណត់ដោយច្បាប់ និងក្នុងផលប្រយោជន៍ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ និងសីលធម៌។ ទីបី គឺបទដ្ឋានសិទ្ធិមនុស្សជាតិ ជាពិសេសរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា គឺទទួលស្គាល់ធានា និងគោរពសិទ្ធិមនុស្សគ្រប់បែបយ៉ាង។ ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញក៏បញ្ញត្តិដែរថា ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ ដោយឡែកទាក់ទងទៅនឹងទោសទណ្ឌ គឺច្បាប់នេះដាក់ទោសតែចំពោះជនខិលខូចឬទុច្ចរិតណាមួយដែលមិនគោរព និងចូលរួមអនុវត្ត ព្រមទាំងមានចេតនាធ្វើឲ្យខូចសណ្តាប់ធ្នាប់សាធារណៈ បង្កអស្ថេរភាពសង្គម និងធ្វើឲ្យប៉ះពាល់ខ្លាំងទៅលើសុខភាពសាធារណៈតែប៉ុណ្ណោះ។

ចំពោះគុណប្រយោជន៍នៃច្បាប់នេះទៅលើសង្គមជាតិ មានដូចជាការការពារនូវផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅកម្ពុជា ការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។

## ២. ការផ្ដល់អនុសាសន៍

នៅក្នុងកិច្ចការប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដ-១៩របស់រាជរដ្ឋាភិបាលនារយៈកាលជាងមួយឆ្នាំកន្លងមកនេះ គឺត្រូវបានមើលឃើញថាមានភាពជោគជ័យ និងបានផលជាផ្លែផ្កាគួជាទីកត់សម្គាល់។ ជាមួយគ្នានេះដែរក៏ត្រូវអរគុណ និងសាទរយ៉ាងខ្លាំងដូចគ្នាចំពោះប្រជាពលរដ្ឋ ព្រោះថាបើគ្មានការចូលរួមអនុវត្តពីសំណាក់ប្រជាពលរដ្ឋទេ ក៏ការអំពាវនាវ និងវិធានការផ្សេងៗរបស់រាជរដ្ឋាភិបាលដែលដាក់ចេញមកមិនមានប្រសិទ្ធភាពនោះដែរ។

តាមរយៈការវិភាគ និងការបកស្រាយកន្លងមកដែលសិក្សាទៅលើប្រធានបទ ″ សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងក្របខណ្ឌច្បាប់កូវីដ-១៩ ″ ក៏សូមធ្វើការលើកឡើងនូវមតិយោបលផ្ទាល់ខ្លួនមួយចំនួនដើម្បីជាការចូលរួមក្នុងការកែលម្អសម្រាប់ជាប្រយោជន៍ចំពោះសង្គមជាតិក៏ដូចជាការកាត់បន្ថយនូវផលប៉ះពាល់ផ្សេងៗនៃជំងឺកូវីដ-១៩មកលើសង្គមកម្ពុជាដុចតទៅ ៖

- គាំទ្រឲ្យរាជរដ្ឋាភិបាលបន្តផ្សព្វផ្សាយអំពីផលវិបាកនៃការឆ្លងជំងឺកូវីដ-១៩មកលើបុគ្គលខ្លួនឯងផ្ទាល់ និងផលប៉ះពាល់នៃជំងឺនេះមកលើវិស័យសង្គម និងសេដ្ឋកិច្ច។
- ត្រូវតែបន្តអនុវត្តផ្សព្វផ្សាយឲ្យបានច្រើន និងមានភាពទូលាយពាក់ព័ន្ធទៅនឹងច្បាប់កូវីដ-១៩ ដើម្បីឲ្យប្រជាពលរដ្ឋបានដឹងពីគោលបំណង ក៏ដូចជាគុណសម្បត្តិនិងគុណវិបត្តិផ្សេងៗទាក់ទងទៅនឹងច្បាប់នេះ។
- នៅក្នុងមាត្រា៩ " បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ ″ គប្បីត្រូវមានការបកស្រាយឲ្យបានច្បាស់ ឬលម្អិតជាងនេះ ព្រោះទាក់ទងទៅនឹងចេតនា ក៏ត្រូវបង្ហាញពីសកម្មភាពចេតនាណាមួយឲ្យបានច្បាស់ ចៀសវាងនូវមតិដូចបានលើកឡើងមកពីខាងលើហើយថា ប្រជាពលរដ្ឋរងគ្រោះដោយសារជំងឺមួយហើយ នូវរងគ្រោះដោយសារទោសទណ្ឌនៃច្បាប់នេះមួយទៀត។
- ពាក់ព័ន្ធនឹងសិទ្ធិ ថាតើគួរត្រូវលើកលែង ឬរឹតបន្តឹងបែបនេះទៅទៀតជាពិសេសដូចជា ការប្រកបរបរបើភោជនីយដ្ឋាន និងក្លឹបកម្សាន្ត ឬក្លឹបកីឡាផ្សេងទៀត ខណៈពេលដែលប្រទេសកម្ពុជាថ្មីៗនេះត្រូវបានរាយការណ៍ថា ជាប្រទេសជាប់ចំណាត់ថ្នាក់លេខមួយក្នុងការសម្រេចបាននូវការចាក់វ៉ាក់សាំងជូនប្រជាជន។

# ឯកសារយោង

## ឯកសារយោង

### រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

### បទដ្ឋានគតិយុត្តអន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងពិធីសារបន្ថែម

### ច្បាប់

- ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- ច្បាប់គ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

### អនុក្រឹត្យ

- អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- អនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- អនុក្រឹត្យស្តីពីវិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

### សេចក្តីសម្រេច

- សេចក្តីសម្រេច ស្តីពីការអនុវត្តវិធានការរដ្ឋបាលជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ នៅភូមិសាស្ត្ររាជធានីភ្នំពេញ, លេខ ០៦៨/២១. សសរ, ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

- សេចក្តីសម្រេច ស្តីពីការហាមឃាត់ការធ្វើដំណើរ និងបិទរមណីយដ្ឋាននៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩, លេខ ៤៤. សសរ, ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១
- សេចក្តីសម្រេច ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩, លេខ ៤៩. សសរ, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

**សៀវភៅ**

- សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ, មេរៀនទី១៣, ចាប់ពីទំព័រ ៣៥៨ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋាន

**គេហទំព័រ**

- អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស https://pressocm.gov.kh/archives
- ក្រសួងយុត្តិធម៌ http://moj.gov.kh/kh/news-event/795
- ក្រសួងមុខងារសាធារណៈ http://www.mcs.gov.kh/?p=22805
- អង្គការយូនីសេហ្វ (Unicef) https://www.unicef.org/cambodia/km
- PS_CLJR MOJ https://youtu.be/VI2HhqcLX_k
- ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស http://cambodia.ohchr.org/kh
- ក្រសួងយុត្តិធម៌ http://moj.gov.kh/kh/news-event/795
- វិទ្យុបារាំងអន្តរជាតិផ្សាយជាភាសាខ្មែរ https://www.rfi.fr/km/
- បណ្ណាល័យអេឡិចត្រូនិក សម្តេចតេជោ ហ៊ុន សែន http://spm-edoc.com/article/870
- New room Cambodia https://newsroomcambodia.com/group-vi/2021/03/22/the-multi-opinions-on-new-law-of-covid19/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិង ប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត

ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លង កាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីវិធានសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លង កាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

# ព្រះរាជក្រម

នស/រកម/០៣២១/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្ដីពី

## វិធានការទប់ស្កាត់ការឆ្លងរាលដាល
## នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ
## និងប្រកបដោយគ្រោះថ្នាក់
## ធ្ងន់ធ្ងរផ្សេងទៀត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះកំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្ត ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់ក្រសួងសុខាភិបាល។

## ជំពូកទី២
## វិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

**មាត្រា៣ .- វិធានការសុខាភិបាល**

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការសុខាភិបាលចាំបាច់នានា មានជាអាទិ៍៖

- ការធ្វើអនាម័យ
- ការពាក់ម៉ាស
- ការរក្សាគម្លាតសុវត្ថិភាពសង្គម
- ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩
- ការធ្វើចត្តាឡីស័ក
- ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
- ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការធ្វើសេចក្ដីប្រកាសសុខភាព និង
- វិធានការសុខាភិបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ខ្លឹមសារលម្អិតនៃវិធានការសុខាភិបាលខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិដល់ក្រសួងសុខាភិបាល ដើម្បីដាក់ចេញនូវវិធានការសុខាភិបាលផ្សេងថែមទៀត សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤ .- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត**

រាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្តោះអាសន្ននូវវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត ដែលមានភាពចាំបាច់និងមានប្រយោជន៍ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានជាអាទិ៍៖

- ការរឹតត្បិតឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិតឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការបិទខ្ទប់តំបន់ឬទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការខាងលើ សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**មាត្រា៥ .- ទណ្ឌកម្ម**

បុគ្គលដែលមិនអនុវត្តតាមវិធានការសុខាភិបាល វិធានការរដ្ឋបាល ឬវិធានការផ្សេងទៀត ដែលត្រូវបានដាក់ចេញស្របតាមច្បាប់នេះ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់នេះ។

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្យួរឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ការបិទអាជីវកម្ម។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

បទល្មើសផ្សេងទៀតដែលត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការសុខាភិបាលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។ ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដែលចេញវិធានការនោះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍រំលត់បណ្តឹងអាជ្ញាចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចស្តីពីការដាក់ពិន័យអន្តរការណ៍ មន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

**មាត្រា៦ .- ក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល**

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលខាងលើ អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីសម្រេចស្តីពីការដាក់ទណ្ឌកម្មនោះ។

ក្នុងករណីបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ បុគ្គលនោះអាចដាក់ពាក្យប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីសម្រេចលើបណ្តឹងតវ៉ា។

ការដាក់ពាក្យប្តឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចស្តីពីការដាក់ទណ្ឌកម្មនោះទេ។

**មាត្រា៧ .- បទគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក**

អំពើគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័កដែលកំណត់ដោយក្រសួងសុខាភិបាលឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលពិន័យអន្តរការណ៍តាមការកំណត់នៅក្នុងអនុក្រឹត្យ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា៨ .- បទគេចវេះពីការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល**

អំពើគេចវេះពីការតម្រូវឱ្យទទួលការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល ដែលកំណត់ដោយក្រសួងសុខាភិបាលឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា៩ .- បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ**

អំពើចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ កាលបើអំពើខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុមឬអង្គការចាត់តាំង។

**មាត្រា១០ .- បទមិនគោរពវិធានការរដ្ឋបាល**

ដោយមិនគិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១១ .- បទរារាំងដល់ការអនុវត្តវិធានការ**

អំពើរារាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១២ .- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៣ .- ករណីលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ**

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃ

ច្បាប់នេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃច្បាប់នេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា១៤ ._ ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៣នៃច្បាប់នេះ មិនរាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៤
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**មាត្រា១៥ ._ ការអនុវត្តដូចគ្នានូវបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត**

វិធានការទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់នេះ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ ._ ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនច្បាប់នេះ**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលច្បាប់នេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .- ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២១

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសប់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

ពរស.៤២១០៣.៤៤៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ម៉ម ប៊ុនហេង** **កើត រិទ្ធ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០២ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### មាត្រា១.- គោលបំណង

អនុក្រឹត្យនេះ កំណត់អំពីវិធានការរដ្ឋបាល ស្របតាមច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## មាត្រា២.. វិសាលភាព

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# វិធានការរដ្ឋបាលដែលត្រូវអនុវត្ត
## ផ្នែកទី១
## ប្រភេទនៃវិធានការរដ្ឋបាល

## មាត្រា៣.. វិធានការរដ្ឋបាលនានា

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការរដ្ឋបាលចាំបាច់នានាដែលត្រូវអនុវត្ត មានជាអាទិ៍៖

- ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិត ឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូលតំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បម្រាមគោចរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ផ្នែកទី២
## ខ្លឹមសារនៃវិធានការរដ្ឋបាល

## មាត្រា៤.. ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ

ការធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម ដែលមិនមានការរឹតត្បិត ឬហាមឃាត់ និងដោយមានភ្ជាប់លិខិតបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម
- ការធ្វើដំណើរទៅស្វែងរកគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រឃុំ-សង្កាត់ដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំប្រមូលផ្តុំមនុស្ស
- ការធ្វើដំណើរដើម្បីអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬសាលាជម្រះក្តី
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើផលប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ជាអាទិ៍ ករណីមានសមាជិកគ្រួសារកំពុងមានជំងឺធ្ងន់ធ្ងរនិងត្រូវសង្គ្រោះបន្ទាន់ ឬករណីមានសមាជិកគ្រួសារទទួលមរណភាព។

**មាត្រា៥ .. ការរឹតត្បិត ឬការហាមឃាត់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស**

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្សដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការជួបជុំមនុស្សដើម្បីផ្តល់ជំនួយចាំបាច់នានាដល់ជនងាយរងគ្រោះ ឬជនរងគ្រោះ
- ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តី និង
- ការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៦ .. ការហាមឃាត់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម**

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានផ្អាកជាបណ្តោះអាសន្ន លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងារនៅក្នុងក្របខណ្ឌមុខងារសាធារណៈ ឬការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈតាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាផ្គត់ផ្គង់អគ្គិសនី, ទឹក, សេវាប្រមូលសំរាម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន
- ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ, ស្ថានីយ៍ប្រេងឥន្ធនៈ, សេវាប្រៃសណីយ៍ និងទូរគមនាគមន៍
- ភោជនីយដ្ឋាន និងអាហារដ្ឋានដែលលក់អាហារវេចខ្ចប់
- សេវាកម្មដឹកជញ្ជូនទំនិញ និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៧ .. ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូល**

ការធ្វើចរាចរណ៍ចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងណាមួយ ដែលមានការឆ្លងរាលដាលជំងឺ

កូវីដ-១៩ អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ។

### មាត្រា៨.- បម្រាមគោចរ

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ការដឹកជញ្ជូនទំនិញ ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ ការធ្វើដំណើរទៅទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ និងសេវាសាធារណៈចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

### មាត្រា៩.- ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

រាល់ការធ្វើដំណើរចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងដែលត្រូវបានបិទខ្ទប់ អាចត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្ដល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងអំឡុងពេលនៃការបិទខ្ទប់ វិធានការរដ្ឋបាលដែលមានចែងក្នុងមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យនេះ ត្រូវបានយកមកអនុវត្តទាំងស្រុង ឬដោយផ្នែក។

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កំដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

### មាត្រា១០.- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

ទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំណត់ដោយក្រសួងសុខាភិបាល អាចត្រូវបានរឹតត្បិត ឬហាមឃាត់ការធ្វើពាណិជ្ជកម្មតាមគ្រប់រូបភាពនៅលើទីផ្សារ និងការផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## សិទ្ធិអំណាចក្នុងការដាក់ចេញវិធានការរដ្ឋបាល

### មាត្រា១១.- សមត្ថកិច្ចក្នុងការដាក់ចេញវិធានការរដ្ឋបាល

ការដាក់ចេញវិធានការបិទខ្ទប់រាជធានីឬខេត្ត និងការដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតដែលមានវិសាលភាពអនុវត្តលើសពីដែនដីនៃរាជធានី ឬខេត្តមួយ ឬមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស ត្រូវធ្វើឡើងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈអភិបាលរាជធានី ខេត្ត ត្រូវបានប្រគល់សមត្ថកិច្ចក្នុងការសម្រេចដាក់ចេញវិធានការរដ្ឋបាលណាមួយដែលមានវិសាលភាពអនុវត្តសម្រាប់ផ្នែកខ្លះ ឬទីកន្លែងខ្លះក្នុងដែនដីនៃរាជធានីខេត្ត ឬមានវិសាលភាពអនុវត្តទូទាំងរាជធានី ឬខេត្តរបស់ខ្លួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

### មាត្រា១២.- លក្ខខណ្ឌនៃការដាក់ចេញវិធានការរដ្ឋបាល

ការដាក់ចេញវិធានការរដ្ឋបាលណាមួយស្របតាមអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាបណ្ដោះអាសន្នសម្រាប់ថិរវេលាមិនឱ្យលើសពី ២ (ពីរ) សប្ដាហ៍។ ថិរវេលានេះអាចត្រូវបានសម្រេចបន្ត ឬបញ្ចប់មុនថិរវេលាកំណត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងការសម្រេចដាក់ចេញវិធានការរដ្ឋបាល ស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ។

### មាត្រា១៣.- សិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវបានប្រគល់ភារកិច្ចក្នុងការធានាការអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី១ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបង្កើតយន្តការចាំបាច់នានា ដើម្បីតាមដាន ត្រួតពិនិត្យ និងអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ ក្រោមសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ អាចចេញសេចក្ដីណែនាំលម្អិតអំពីការអនុវត្តវិធានការរដ្ឋបាលនានាដែលបានដាក់ចេញស្របតាមអនុក្រឹត្យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបន្ធូរបន្ថយនូវវិធានការរដ្ឋបាលណាមួយដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី២ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ប៉ុន្តែត្រូវគោរពឱ្យបាននូវរាល់លក្ខខណ្ឌលើកលែងដាក់លាក់នៃវិធានការរដ្ឋបាលនីមួយៗ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្នុងករណីបន្ទាន់និងចាំបាច់ គណៈអភិបាលរាជធានី ខេត្តមានសិទ្ធិដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតសំដៅធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

### មាត្រា១៤.- ទណ្ឌកម្មចំពោះអំពើមិនគោរពវិធានការរដ្ឋបាល

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១០ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនគោរពដោយចេតនានូវវិធានការរដ្ឋបាលដែលមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បែបបទនីតិវិធីលម្អិតសម្រាប់ការដាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយគណៈអភិបាលរាជធានី ខេត្ត។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### មាត្រា១៥.- ទណ្ឌកម្មចំពោះអំពើរារាំងដល់ការអនុវត្តវិធានការរដ្ឋបាល

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលប្រព្រឹត្តអំពើរារាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការរដ្ឋបាលដូចមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

**មាត្រា១៦ .. ទណ្ឌកម្មចំពោះអំពើមិនគោរពវិធានការសុខាភិបាល**

ត្រូវផ្តន្ទាទោសស្របតាមមាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា១៧ .. ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃអនុក្រឹត្យនេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៨ .. ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ**

ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា១៩ .. ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបទប្បញ្ញត្តិជំពូកទី៤ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៥
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**មាត្រា២០ .. ការអនុវត្តដូចគ្នានូវបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត**

វិធានការរដ្ឋបាលទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

### មាត្រា២១ .- ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនអនុក្រឹត្យនេះ

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

### មាត្រា២២ .- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

### មាត្រា២៣ .- ស្ថាប័នអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## វិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះ កំណត់អំពីវិធានការសុខាភិបាលស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់ក្រសួងសុខាភិបាល។

## ជំពូកទី២
## ប្រភេទនៃវិធានការសុខាភិបាល

**មាត្រា៣ ..**

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការសុខាភិបាលចាំបាច់នានាដែលត្រូវអនុវត្ត មានជាអាទិ៍៖

- ការធ្វើអនាម័យ និងការវាស់កំដៅ
- ការពាក់ម៉ាស
- ការរក្សាគម្លាតសុវត្ថិភាពបុគ្គល និងសង្គម
- ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩
- ការធ្វើចត្តាឡីស័ក
- ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
- ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការធ្វើសេចក្តីប្រកាសសុខភាព និង
- ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩។

## ជំពូកទី៣
## ខ្លឹមសារនៃវិធានការសុខាភិបាល
### ផ្នែកទី១
### ការធ្វើអនាម័យ ការវាស់កំដៅ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព

**មាត្រា៤ ..**

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវរៀបចំឱ្យមានការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កំដៅបុគ្គលម្នាក់ៗ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ក្នុងគោលបំណងដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

បុគ្គលគ្រប់រូប ត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព នៅតាមទីសាធារណៈ ឬទីកន្លែងដែលមានការជួបជុំមនុស្ស ដើម្បីបង្ការការចម្លងឬការឆ្លងមេរោគកូវីដ-១៩។

**មាត្រា៥ ..**

ការពាក់ម៉ាស ត្រូវធ្វើជាកាតព្វកិច្ចដោយផ្អែកតាមសកម្មភាពការងារ ឬស្ថានភាពមុខរបររបស់បុគ្គល និងនៅតាមទីកន្លែងដែលមានហានិភ័យនៃការចម្លងឬការឆ្លងមេរោគកូវីដ-១៩។

បុគ្គលដែលមានកាតព្វកិច្ចពាក់ម៉ាស និងទីកន្លែងដែលតម្រូវឱ្យមានការពាក់ម៉ាស ត្រូវកំណត់ដោយក្រសួងសុខាភិបាល ដោយផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**មាត្រា៦ ..**

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវត្រួតពិនិត្យ និងណែនាំបុគ្គលិក និងបុគ្គលគ្រប់រូប ដែលចូលទៅទីកន្លែងរបស់ខ្លួន ឱ្យធ្វើអនាម័យដើម្បីសម្លាប់មេរោគ វាស់កំដៅ និងពាក់ម៉ាស តាមការកំណត់របស់ក្រសួងសុខាភិបាល។

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម មិនត្រូវអនុញ្ញាតឱ្យបុគ្គលដែលមិនធ្វើអនាម័យដើម្បីសម្លាប់មេរោគ បុគ្គលដែលមានសីតុណ្ហភាពក្នុងខ្លួនលើសពី ៣៧,៥ (សាមសិបប្រាំពីរក្បៀសប្រាំ) អង្សាសេ ឬបុគ្គលណាដែលមិនពាក់ម៉ាស ចូលក្នុងនិងស្ថិតនៅក្នុងទីកន្លែងរបស់ខ្លួនឡើយ។

**មាត្រា៧ ..**

ការរក្សាគម្លាតសុវត្ថិភាពបុគ្គល ត្រូវមានយ៉ាងតិច ១,៥០ ម៉ែត្រ(មួយម៉ែត្រក្បៀសហាសិបសង់ទីម៉ែត្រ) ហើយត្រូវអនុវត្តជាកាតព្វកិច្ចនៅទីកន្លែងធ្វើការ ទីតាំងអាជីវកម្ម ឬទីកន្លែងសាធារណៈនានាដែលមានមនុស្សច្រើន តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក្នុងករណីដែលការរក្សាគម្លាតសុវត្ថិភាពបុគ្គល មិនអាចធ្វើទៅបានដោយមូលហេតុ ជាអាទិ៍ សុខភាពកាយសម្បទា សកម្មភាពការងារ ស្ថានភាពមុខរបរ ឬកាលៈទេសៈនៃសកម្មភាព បុគ្គលនោះត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការពាក់ម៉ាស។

រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ត្រូវរៀបចំនៅក្នុងទីកន្លែងរបស់ខ្លួន ដើម្បីធានាថាបុគ្គលិក និងអតិថិជន អាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល នៅពេលរង់ចាំចូល និងពេលកំពុងស្ថិតក្នុងទីកន្លែងរបស់ខ្លួន។ រាល់សហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម មិនត្រូវទទួលអតិថិជនលើសពីចំនួនដែលអាចរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គលនៅក្នុងទីកន្លែងរបស់ខ្លួនឡើយ។

អ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀតជាអាទិ៍ កម្មវិធីសាសនា កម្មវិធីប្រពៃណី កម្មវិធីកីឡា ឬកម្មវិធីកំសាន្ត ជាដើម ត្រូវរក្សាគម្លាតសុវត្ថិភាពសង្គម ដោយត្រូវកាត់បន្ថយចំនួនអ្នកចូលរួមឱ្យនៅកម្រិតអប្បបរមា និងចៀសវាងការជួបជុំដែលមានលក្ខណៈកុះករកកកុញ ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ផ្អែកលើកម្រិតនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**មាត្រា៨ ..**

វិធានដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ ក៏ត្រូវយកទៅអនុវត្តដូចគ្នាផងដែរចំពោះទីតាំង ឬគ្រឹះស្ថានសាធារណៈ ដើម្បីជាវិធានការការពារកុំឱ្យមានការចម្លង ឬការឆ្លងមេរោគកូវីដ-១៩។

## ផ្នែកទី២

## ការធ្វើសេចក្តីប្រកាសសុខភាព ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័ក ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល

**មាត្រា៩ ..**

ពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬជាមួយអ្នកដែលសង្ស័យថាមាន

ផ្ទុកមេរោគកូវីដ-១៩ ត្រូវធ្វើសេចក្ដីប្រកាសសុខភាពដោយបំពេញទម្រង់ប្រកាសសុខភាពដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច និងតាមរយៈការផ្ដល់ព័ត៌មានចាំបាច់ផ្សេងទៀត តាមការសាកសួររបស់មន្ត្រីសុខាភិបាល ឬមន្ត្រីជំនាញមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល ពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដល់លិខិតបញ្ជាក់សុខភាពដែលបញ្ជាក់ថាគ្មានមេរោគកូវីដ-១៩ មានសុពលភាពរយៈពេល ៧២(ចិតសិបពីរ)ម៉ោង មុនពេលធ្វើដំណើរ ចេញដោយអាជ្ញាធរដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសដែលខ្លួនស្ថិតនៅមុនពេលធ្វើដំណើរ ឬលិខិតបញ្ជាក់ផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខាភិបាល។

**មាត្រា១០.-**

បុគ្គលគ្រប់រូបដែលស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម មានកាតព្វកិច្ចត្រូវផ្ដល់វត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដល់មន្ត្រីសុខាភិបាលមានសមត្ថកិច្ច៖

- ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា តាមគ្រប់មធ្យោបាយ
- បុគ្គលដែលត្រូវមន្ត្រីសុខាភិបាលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩
- បុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកមានផ្ទុកមេរោគកូវីដ-១៩
- បុគ្គលដែលបានប៉ះពាល់ដោយប្រយោលជាមួយអ្នកមានផ្ទុកមេរោគកូវីដ-១៩
- បុគ្គលដែលកំពុងស្ថិតក្នុងការធ្វើចត្តាឡីស័ក និង
- អ្នកជំងឺកូវីដ-១៩ ដែលកំពុងស្ថិតក្នុងការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល។

**មាត្រា១១.-**

ការធ្វើចត្តាឡីស័ក ត្រូវអនុវត្តចំពោះរាល់ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ និងបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬជាមួយអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល។

ការធ្វើចត្តាឡីស័ក ត្រូវធ្វើនៅក្នុងទីកន្លែងធ្វើចត្តាឡីស័កណាមួយ ឬនៅលំនៅឋានរបស់បុគ្គលដែលត្រូវធ្វើចត្តាឡីស័ក តាមការណែនាំរបស់ក្រសួងសុខាភិបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច ដោយផ្អែកលើស្ថានភាពបុគ្គល ស្ថានភាពគ្រួសារ និងស្ថានភាពលំនៅឋានរបស់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កនោះ។

**មាត្រា១២.-**

ការធ្វើចត្តាឡីស័កពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ មានរយៈពេល ១៤ (ដប់បួន) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រសួងសុខាភិបាល។

**មាត្រា១៣.-**

ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក បុគ្គលដែលធ្វើចត្តាឡីស័ក ត្រូវអនុវត្តកាតព្វកិច្ច ដូចខាងក្រោម៖

១- គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងធ្វើចត្តាឡីស័ក

២- អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល

៣- គោរពតាមការណែនាំរបស់មន្ត្រីចត្តាឡីស័ក

៤- មិនត្រូវចាកចេញពីទីកន្លែងធ្វើចត្តាឡីស័ក ដោយគ្មានការអនុញ្ញាតពីមន្ត្រីចត្តាឡីស័ក

៥- សហការជាមួយមន្ត្រីសុខាភិបាលដើម្បីធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និង

៦-សហការក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីសុខាភិបាល អំពីបុគ្គលដែលសង្ស័យថាអាចមានជំងឺកូវីដ-១៩ ឬអ្នកដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬអ្នកដែលត្រូវធ្វើចត្តាឡីស័ក និងផ្តល់ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

**មាត្រា១៤ ..**

បុគ្គលដែលមានផ្ទុកមេរោគកូវីដ-១៩ ត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាលនៅទីកន្លែងណាមួយដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល។

ក្នុងអំឡុងពេលនៃការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល អ្នកជំងឺកូវីដ-១៩ ត្រូវអនុវត្តកាតព្វកិច្ច ដូចខាងក្រោម៖

១- គោរពបទបញ្ជាផ្ទៃក្នុងនៅទីកន្លែងព្យាបាល

២- អនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល តាមការកំណត់របស់ក្រសួងសុខាភិបាល

៣- ត្រូវគោរពតាមការណែនាំរបស់គ្រូពេទ្យក្នុងការព្យាបាល

៤- មិនត្រូវចាកចេញពីទីកន្លែងព្យាបាល ដោយគ្មានការអនុញ្ញាតពីមន្ត្រីសុខាភិបាល

៥- ត្រូវសហការជាមួយមន្ត្រីសុខាភិបាលដើម្បីធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និង

៦-សហការក្នុងការផ្តល់ព័ត៌មានដល់មន្ត្រីសុខាភិបាល អំពីបុគ្គលដែលសង្ស័យថាអាចមានជំងឺកូវីដ-១៩ ឬអ្នកដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ និងផ្តល់ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

## ផ្នែកទី៣
## ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩

**មាត្រា១៥ ..**

ក្នុងករណីដែលមានការសង្ស័យថាសាកសពអាចមានផ្ទុកមេរោគកូវីដ-១៩ គ្រួសារសពត្រូវផ្តល់កិច្ចសហការដល់មន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាកពីសពយកទៅវិភាគរកមេរោគកូវីដ-១៩។ ក្នុងអំឡុងពេលរង់ចាំលទ្ធផលនៃការវិភាគ សាកសពត្រូវស្ថិតក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ក្រសួងសុខាភិបាលដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីដែលលទ្ធផលនៃការវិភាគវត្ថុសំណាកបញ្ជាក់ថាសាកសពគ្មានផ្ទុកមេរោគកូវីដ-១៩ នោះទេ ក្រសួងសុខាភិបាលត្រូវប្រគល់សាកសពឱ្យគ្រួសារសពដើម្បីគ្រប់គ្រង និងចាត់ចែងបន្ត។

ការគ្រប់គ្រង និងចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ដោយមិនអនុញ្ញាតឱ្យគ្រួសារសពជាអ្នកគ្រប់គ្រង និងចាត់ចែងឡើយ។

ដើម្បីបង្ការកុំឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ សាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ត្រូវយកទៅបូជា ឬបញ្ចុះទៅតាមប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា ប៉ុន្តែត្រូវអនុវត្តតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល រួមមានជាអាទិ៍៖ ការរៀបចំសាកសពតាមវិធានសុខាភិបាល ការដឹកជញ្ជូនសាកសព និងការកម្រិតចំនួនអ្នកចូលរួមនៅពេលបូជាឬបញ្ចុះសាកសព។

ការបូជាសាកសពឬការបញ្ចុះសាកសព ត្រូវធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបានដោយគ្មានបង្អង់នៅទីកន្លែងណាមួយតាមការកំណត់របស់អាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថកិច្ច។ អាជ្ញាធរថ្នាក់ក្រោមជាតិមាន

សមត្ថកិច្ច ត្រូវរៀបចំឱ្យមានការសម្គាល់អត្តសញ្ញាណអដ្ឋិធាតុរបស់សាកសព ឬទីបញ្ចុះរបស់សាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ឱ្យបានច្បាស់លាស់។

ក្រសួងសុខាភិបាល ត្រូវធ្វើការណែនាំលម្អិតអំពីវិធានសុវត្ថិភាពផ្នែកសុខាភិបាលទាក់ទងនឹងការគ្រប់គ្រង និងការចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ដើម្បីបង្ការកុំឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

## ផ្នែកទី៤
## ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩

**មាត្រា១៦.-**

ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ត្រូវធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត។ ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់ប្រជាពលរដ្ឋខ្មែរ ត្រូវធ្វើឡើងដោយឥតគិតថ្លៃ។

ការចាក់វ៉ាក់សាំងអាចត្រូវធ្វើឡើងជាចាំបាច់ចំពោះបុគ្គលមួយចំនួន ដោយផ្អែកលើស្ថានភាពនៃការងារ ឬស្ថានភាពនៃមុខរបររបស់បុគ្គលនោះ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលអាចដាក់ចេញនូវវិធានការតម្រូវឱ្យអ្នកដំណើរជាជនបរទេសដែលធ្វើដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានប័ណ្ណបញ្ជាក់ពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ពេញលេញ។ ការទទួលស្គាល់ប័ណ្ណបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

បុគ្គលដែលបានទទួលការចាក់វ៉ាក់សាំងត្រឹមត្រូវតាមការកំណត់របស់ក្រសួងសុខាភិបាល អាចទទួលបានលក្ខខណ្ឌអនុគ្រោះក្នុងការអនុវត្តកាតព្វកិច្ចតាមវិធានសុខាភិបាលនានា ដែលកំណត់ដោយក្រសួងសុខាភិបាល។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលត្រូវចេញសេចក្តីណែនាំអំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤
## វិធានការសុខាភិបាលផ្សេងទៀត

**មាត្រា១៧.-**

ក្រសួងសុខាភិបាលអាចចេញសេចក្តីណែនាំលម្អិតអំពីការអនុវត្តវិធានការសុខាភិបាលនានា ដែលមានចែងក្នុងអនុក្រឹត្យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត។

ក្នុងករណីបន្ទាន់និងចាំបាច់ ក្រសួងសុខាភិបាលអាចដាក់ចេញនូវវិធានការសុខាភិបាលផ្សេងថែមទៀតសំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

## ជំពូកទី៥
## កម្រៃទាក់ទងនឹងការអនុវត្តវិធានការសុខាភិបាល

**មាត្រា១៨.-**

កម្រៃនានាក្នុងអំឡុងពេលធ្វើចត្តាឡីស័ក និងការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ព្រមទាំងកម្រៃផ្សេងទៀតទាក់ទងនឹងការអនុវត្តវិធានការសុខាភិបាល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា១៩ ..**

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ចំពោះបុគ្គលដែលមិនអនុវត្តនូវកាតព្វកិច្ចពាក់ម៉ាសដូចមានចែងក្នុងមាត្រា៥ ឬកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គលដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ២០០.០០០ (ពីរសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ចំពោះអ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលមិនគោរពវិធានការរក្សាគម្លាតសុវត្ថិភាពសង្គម ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់ចេញនូវវិធានការរដ្ឋបាលបន្ថែមដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះអ្នកទទួលខុសត្រូវក្នុងការរៀបចំការជួបជុំមនុស្ស ឬសកម្មភាពសង្គមដទៃទៀត ដែលបានប្រព្រឹត្តអំពើល្មើសខាងលើ។

**មាត្រា២០ ..**

ត្រូវធ្វើការព្រមាន និងធ្វើការណែនាំដោយមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច ចំពោះសហគ្រាស ឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលមិនបានអនុវត្តកាតព្វកិច្ចទាក់ទងនឹងការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ។ ក្នុងករណីនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលបន្ថែមដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះសហគ្រាសឬគ្រឹះស្ថានឯកជន ឬម្ចាស់អាជីវកម្ម ដែលបានប្រព្រឹត្តអំពើល្មើសខាងលើ។

**មាត្រា២១ ..**

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលមិនសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យបុគ្គលដែលប្រព្រឹត្តអំពើល្មើសនេះ រួចផុតពីកាតព្វកិច្ចក្នុងការឱ្យមន្ត្រីសុខាភិបាលយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ នោះទេ។

**មាត្រា២២ ..**

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក តែមិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

អំពើគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ដែលបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ ត្រូវផ្តន្ទាទោសតាមកថាខណ្ឌទី២ នៃមាត្រា ៧

នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ៥០០.០០០ (ប្រាំសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ចំពោះបុគ្គលដែលធ្វើចត្តាឡីស័ក ដែលមិនអនុវត្តនូវកាតព្វកិច្ចដូចមានចែងក្នុងចំណុចទី១ និងទី២ នៃមាត្រា១៣ នៃអនុក្រឹត្យនេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍ខាងលើនេះ មិនធ្វើឱ្យបុគ្គលដែលត្រូវធ្វើចត្តាឡីស័ក រួចផុតពីកាតព្វកិច្ចក្នុងការធ្វើចត្តាឡីស័កឡើយ។

**មាត្រា២៣.-**

ត្រូវពិន័យអន្តរការណ៍ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះអ្នកផ្តើមគំនិត ដឹកនាំ ណែនាំ ញុះញង់ បញ្ចុះបញ្ចូល ឬជួយសម្រួលដោយចេតនា ដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កឱ្យគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីកន្លែងធ្វើចត្តាឡីស័ក ក្នុងករណីដែលការគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬការគេចវេះពីការធ្វើចត្តាឡីស័ក ឬការគេចចេញពីកន្លែងធ្វើចត្តាឡីស័ក មិនបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា២៤.-**

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះអ្នកជំងឺកូវីដ-១៩ ដែលត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល ដែលមិនអនុវត្តនូវកាតព្វកិច្ច ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃកថាខណ្ឌទី២ នៃមាត្រា១៤ នៃអនុក្រឹត្យនេះ។

**មាត្រា២៥.-**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ចំពោះបុគ្គលដែលបានចាត់ចែងសាកសពដែលមានផ្ទុកមេរោគកូវីដ-១៩ ល្មើសនឹងមាត្រា១៥ នៃអនុក្រឹត្យនេះ។

**មាត្រា២៦.-**

ត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះគ្រឹះស្ថានសុខាភិបាលឯកជនទាំងអស់ ដែលមិនបានធ្វើការជូនដំណឹងបន្ទាន់ទៅក្រសួងសុខាភិបាល ក្នុងករណីពិនិត្យឃើញថា អ្នកជំងឺដែលកំពុងទទួលសេវាព្យាបាលនៅក្នុងគ្រឹះស្ថានរបស់ខ្លួនមានតម្រុយបញ្ជាក់ថាជាអ្នកជំងឺដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬកំពុងគេចចេញពីកន្លែងធ្វើចត្តាឡីស័ក។

**មាត្រា២៧.-**

ប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់ពីមាត្រា២១ ដល់មាត្រា២៦ នៃអនុក្រឹត្យនេះ ត្រូវកើនឡើងទ្វេដង ក្នុងករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត។

ការសម្រេចអំពីប្រាក់ពិន័យអន្តរការណ៍ក្នុងករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្តងទៀត ត្រូវកើនយ៉ាងតិចទ្វេដងនៃប្រាក់ពិន័យដែលបានសម្រេចលើកមុន និងក្នុងកម្រិតអតិបរមានៃប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ។

**មាត្រា២៨.-**

ការពិន័យអន្តរការណ៍ដែលមានចែងក្នុងអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២៩.-**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃអនុក្រឹត្យនេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣០.-**

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា៣១.-**

ការអនុវត្តបទប្បញ្ញត្តិជំពូកទី៦ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៧
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

**មាត្រា៣២.-**

វិធានការសុខាភិបាលទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៣.-**

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការសុខាភិបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៤ ..**

អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីវិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវទុកជានិរាករណ៍ និងជំនួសទាំងស្រុងដោយអនុក្រឹត្យនេះ។

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ម៉ម ប៊ុនហេង** **កើត រិទ្ធ**

**__កន្លែងទទួល៖__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ